# អគ្គិសនីកម្ពុជា

## នាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ

# របាយការណ៍

# ស្តីពី

# ការរុញផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ

# ប្រចាំឆ្នាំ២០២៣



*រៀបចំដោយនាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ២០២៤*

admin@ref.gov.kh
www.ref.gov.kh

# សារពី
# ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
# ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា

## សារពី
## ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
## ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា



ថាមពលអគ្គិសនី គឺជាតម្រូវការចាំបាច់បំផុតដែលមិនអាចខ្វះបានសម្រាប់មនុស្សជាតិនៅគ្រប់ទីកន្លែងក្នុងយុគសម័យថ្មីនេះ ជាពិសេសបច្ចេកវិទ្យាកាន់តែទំនើប ធ្វើឱ្យបរិមាណប្រើប្រាស់កាន់តែកើនឡើងឥតឈប់ឈរសម្រាប់បម្រើជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង។

នៅឆ្នាំ១៩៩៨ ប្រទេសកម្ពុជាយើងទទួលបានសុខសន្តិភាពពេញលេញទូទាំងប្រទេស ដោយសារគោលនយោបាយឈ្នះឈ្នះរបស់សម្តេចតេជោ វិស័យអគ្គិសនីក៏ដូចជាវិស័យផ្សេងៗទៀតបានចាប់ផ្តើមអភិវឌ្ឍជាលក្ខណៈទូលំទូលាយ។ ស្របពេលនេះមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទចាប់ផ្តើមដំណើរការពេលដំបូងនៅឆ្នាំ២០០៤ ជាទូទៅអត្រាថ្លៃអគ្គិសនីមានកម្រិតខ្ពស់ ហើយនៅតំបន់ជនបទខ្ពស់ជាងច្រើនដង ធៀបនឹងនៅរាជធានីភ្នំពេញ ជាពិសេសតំបន់ដាច់ស្រយាលខ្លះដូចជា តំបន់កោះដែលធ្វើឱ្យមានអត្រាផ្គត់ផ្គង់ទាបនៅទូទាំងប្រទេស ហើយនៅឆ្នាំ២០០៨ មានតែ ១៧%ប៉ុណ្ណោះ។ ចាប់តាំងពីឆ្នាំ២០១៦ ប្រទេសកម្ពុជាយើងទទួលបានការឯកភាពថ្លៃទូទាំងប្រទេស ទោះបីជាប្រជាពលរដ្ឋរស់នៅតំបន់ជនបទ ក៏ដូចជាតាមបណ្តាទីប្រជុំជននៅក្នុងរាជធានី-ខេត្ត អាចទទួលបានអគ្គិសនីប្រើប្រាស់ដែលមានតម្លៃសមរម្យ ហើយអត្រាផ្គត់ផ្គង់នៅឆ្នាំ២០២៤ គឺកើនទៅដល់ ៩៥% ពីបណ្តាញជាតិ។

យើងខ្ញុំមានកិត្តិយសសូមបង្ហាញរបាយការណ៍ប្រចាំឆ្នាំរបស់នាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃអគ្គិសនីកម្ពុជា សម្រាប់ឆ្នាំ២០២៣ ដែលក្នុងនោះ នាយកដ្ឋានបានទទួលថវិកាចំនួន ៤៧៤,២៥ ប៊ីលានរៀល ពីអគ្គិសនីកម្ពុជា សម្រាប់អនុវត្តបន្សាបថ្លៃលក់ដែលជាកម្មវិធីរុញផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ ដែលបានជួយដល់បងប្អូនប្រជាពលរដ្ឋជាង ២លាន លំនៅឋានទូទាំងប្រទេស ជាពិសេសតំបន់ដាច់ស្រយាលឱ្យទទួលបានថ្លៃលក់អគ្គិសនីដូចៗគ្នា ហើយក៏មានកម្មវិធីផ្សេងៗដូចជា៖

- ការផ្តល់អគ្គិសនីដល់គ្រួសារមានជីវភាពទាប ដែលពុំអាចមានលទ្ធភាពទិញសម្ភារបរិក្ខារ ដើម្បីភ្ជាប់ និងប្រើប្រាស់អគ្គិសនីបាន គឺនាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ បានផ្តល់ជាអំណោយនូវខ្សែចម្លងអគ្គិសនីពីនាឡិកាស្ទង់ដល់ផ្ទះ រួមនឹងបរិក្ខារដូចជា អំពូលភ្លើង ឌីស្យុងទ័រ ប្រអប់ឌីស្យុងទ័រ កុងតាក់-ព្រី និងខ្សែចម្លងអគ្គិសនីក្នុងផ្ទះបានចំនួន ១.៨៤៨ គ្រួសារ ហើយចំនួននេះបានកើនឡើងដល់ ៨៣.៥២២ គ្រួសារ តាំងពីកម្មវិធីដំបូង។
- ការផ្តល់ប្រព័ន្ធផលិតថាមពលពីពន្លឺព្រះអាទិត្យ ជូនដល់គ្រួសារនៅតាមតំបន់ដែលពុំអាចសាងសង់ខ្សែបណ្តាញអគ្គិសនីទៅដល់ ឬមានប្រសិទ្ធភាពទាបបំផុតដូចជា តំបន់ភូមិបណ្តែតទឹកក្នុងបឹងទន្លេសាប តំបន់កោះ និងតំបន់ដាច់ស្រយាល ដែលរួមមានប្រព័ន្ធកំលាំង ៥០០វ៉ាត់ និងឆ្នាំងដាំបាយអគ្គិសនីចំណុះ៤លីត្រមានចំនួន ១.០៣៧ គ្រឿង រួមជាមួយប្រព័ន្ធពន្លឺព្រះអាទិត្យកំលាំង ៥០វ៉ាត់ បានចំនួន ៦៨៥ គ្រឿង។ ការផ្តល់ប្រព័ន្ធពន្លឺព្រះអាទិត្យគឺមានចំនួន ១១៩.៨៩៤ គ្រឿង តាំងពីកម្មវិធីចាប់ផ្តើម។
- បានកែលម្អហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដោយផ្តល់ជូនសេវាករចំនួន ២៨ ដែលបានកែលម្អប្រព័ន្ធបណ្តាញអគ្គិសនីទាំងតង់ស្យុងមធ្យម និងតង់ស្យុងទាបប្រវែង ៥៥៣,៤៥ គីឡូម៉ែត្រ ដែលនាំឱ្យមានការផ្គត់ផ្គង់ចែកចាយរឹតតែមានលក្ខណៈប្រសើរឡើងចំនួន ៦.៦៦៥គ្រួសារ។

-អនុគ្រោះថ្លៃអគ្គិសនីសម្រាប់អ្នកប្រើប្រាស់ប្រភេទកសិកម្ម ដោយផ្តល់នូវតម្លៃអនុគ្រោះ ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង ដល់អ្នកប្រើប្រាស់ក្នុងវិស័យកសិកម្ម ចាប់ពីម៉ោង៩យប់ដល់ម៉ោង៧ព្រឹក បានចំនួន ៩៥ អ្នកប្រើប្រាស់ថ្មី ដែលកើនឡើង ១.២៦៣ អតិថិជន ចាប់ពីកម្មវិធីបង្កើត។

ភាពជោគជ័យនេះ គឺទទួលបានពីការគាំទ្រចង្អុលបង្ហាញជាយុទ្ធសាស្ត្រពីរាជរដ្ឋាភិបាល ដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** តាមរយៈក្រសួងរ៉ែ និងថាមពល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការ ក៏ដូចជាស្ថាប័នពាក់ព័ន្ធ អាជ្ញាធរអគ្គិសនីកម្ពុជា សេវាករទូទាំងប្រទេស និងដៃគូអភិវឌ្ឍន៍នានា ព្រមទាំងការខិតខំយ៉ាងសកម្មរបស់មន្ត្រីនិយោជិតយើងទាំងអស់គ្នា ហើយក្នុងនាមជាអគ្គនាយកអគ្គិសនីកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត។ អគ្គិសនីកម្ពុជានឹងបន្តការគាំទ្រដល់ចក្ខុវិស័យ និងបេសកកម្មនេះ ដើម្បីបន្តផ្គត់ផ្គង់អគ្គិសនីទៅដល់បងប្អូនប្រជាពលរដ្ឋគ្រប់គ្រួសារមិនថារស់នៅទីណាក្នុងប្រទេសកម្ពុជារហូតដល់អត្រាចុងក្រោយនៃការផ្គត់ផ្គង់ជាអតិបរមាពីបណ្តាញជាតិឱ្យទទួលបានការប្រើប្រាស់អគ្គិសនីមានស្ថិរភាព និងនិរន្តរភាព។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

បណ្ឌិត. ប្រាំង_ជលសា

# មាតិកា

ទំព័រ

**ព័ត៌មានស្តីពីសមិទ្ធិផលវឌ្ឍនភាព និងការវិភាគនៃកម្មវិធីនីមួយៗដែលអនុវត្តដោយនាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ** ................. ៨

១.១ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ........................................................ ៩

១.២ កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ.................................................. ១១

១.៣ កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ............. ១៣

១.៤ កម្មវិធីផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនីដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយប្រព័ន្ធបណ្តាញជាតិដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទ ក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២៣ តាមបណ្តាខេត្ត និងរាជធានី........................................................................... ១៦

១.៥ កម្មវិធីអនុវត្តអត្រាថ្លៃលក់អនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង៧:០០ព្រឹក សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទក្នុងវិស័យកសិកម្មក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនី ដែលទទួលប្រភពពីបណ្តាញជាតិ ............ ១៧

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធ១ : គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនី និងគោលនយោបាយពាក់ព័ន្ធជាមួយការអភិវឌ្ឍតំបន់ជនបទ និងការប្រើប្រាស់ថាមពលកកើតឡើងវិញ**

១.១ គោលនយោបាយវិស័យថាមពលរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា

១.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនីរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា

**ឧបសម្ព័ន្ធ២ : ព័ត៌មានស្តីពីមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ**

២.១ ការបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ

២.២ រចនាសម្ព័ន្ធគ្រប់គ្រង

២.៣ បណ្ណាល័យ

២.៤ អាសយដ្ឋាន

២.៥ ប្រភពមូលនិធិ

២.៦ ថវិកាជំនួយដែល ម.អ.ជ. បានទទួល និងប្រើប្រាស់

**ឧបសម្ព័ន្ធ៣ : ព័ត៌មានស្តីពីគោលបំណង បេសកកម្ម និងកម្មវិធីរុញផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទរបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ**

៣.១ គោលបំណង

៣.២ បេសកកម្ម

៣.៣ កម្មវិធីរុញផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ

៣.៣.១ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ

៣.៣.២ កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ

៣.៣.៣ កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ

៣.៣.៤ កម្មវិធីផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនី ដែលបានភ្ជាប់ប្រភពអគ្គិសនី ជាមួយប្រព័ន្ធបណ្តាញជាតិ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទ ក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី ក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ ឆ្នាំ២០១៥ ដល់ឆ្នាំ២០២៣ តាមបណ្តាខេត្ត និងរាជធានី

៣.៣.៥ កម្មវិធីអនុវត្តអត្រាថ្លៃលក់អនុគ្រោះពិសេស ៤៨០រៀលក្នុង ១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ ក្នុងវិស័យកសិកម្មក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីដែលទទួលប្រភពពីបណ្ដាញជាតិ

**ឧបសម្ព័ន្ធទី៤** : ព័ត៌មានសង្ខេបស្ដីពី ម.អ.ជ. បានចុះកិច្ចសន្យាជាមួយសេវាករតាមខេត្តនីមួយៗ ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ សម្រាប់ផ្ដល់សម្ភារអគ្គិសនីជាអំណោយជូនគ្រួសារជនបទ ដើម្បីតភ្ជាប់ចរន្តដល់ផ្ទះគ្រួសារជនបទ ក្រោមកម្មវិធីផ្ដល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្ដល់សម្ភារអគ្គិសនីជាអំណោយ ក្នុង១ខ្នងផ្ទះ ក្នុងឆ្នាំ ២០២៣

**ឧបសម្ព័ន្ធទី៥** : ព័ត៌មានសង្ខេបស្ដីពីចំនួនគ្រួសារជនបទ គ្រោងតភ្ជាប់ចរន្តអគ្គិសនីជាប់កិច្ចសន្យា ចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តថ្មី និងស្ថានភាពបច្ចុប្បន្ន ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីផ្ដល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្ដល់សម្ភារអគ្គិសនីជាអំណោយ ក្នុង១ខ្នងផ្ទះ ក្នុងឆ្នាំ២០២៣

**ឧបសម្ព័ន្ធទី៦** : បញ្ជីឈ្មោះភូមិតាមខេត្តនីមួយៗ ដែលគ្របដណ្ដប់តាមខេត្តនីមួយៗ ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីផ្ដល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្ដល់សម្ភារអគ្គិសនីជាអំណោយ ក្នុង១ខ្នងផ្ទះ ក្នុងឆ្នាំ២០២៣

**ឧបសម្ព័ន្ធទី៧** : ផែនទីបង្ហាញពីខេត្តដែលបានអនុវត្តកម្មវិធីផ្ដល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រដោយ ផ្ដល់សម្ភារអគ្គិសនីជាអំណោយ ក្នុង១ខ្នងផ្ទះ ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្នុងឆ្នាំ២០២៣

**ឧបសម្ព័ន្ធទី៨** : បញ្ជីឈ្មោះភូមិដែល ម.អ.ជ. បានដំឡើងប្រព័ន្ធសូឡា ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា ក្នុងឆ្នាំ២០២៣

**ឧបសម្ព័ន្ធទី៩** : ផែនទីបង្ហាញពីខេត្តបានដំឡើងប្រព័ន្ធសូឡា ក្នុងឆ្នាំ២០២៣

**ឧបសម្ព័ន្ធទី១០** : ព័ត៌មានសង្ខេបស្ដីពីចុះកិច្ចសន្យាតាមខេត្តនីមួយៗ ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីជួយទុនពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២៣

**ឧបសម្ព័ន្ធទី១១** : ព័ត៌មានសង្ខេបស្ដីពីប្រវែងខ្សែបណ្ដាញគ្រោងសាងសង់ជាប់កិច្ចសន្យា ប្រវែងខ្សែបណ្ដាញបានសាងសង់រួច និងស្ថានភាពបច្ចុប្បន្នតាមខេត្តនីមួយៗ ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២៣

**ឧបសម្ព័ន្ធទី១២** : បញ្ជីឈ្មោះភូមិតាមខេត្តនីមួយៗដែលគ្របដណ្ដប់តាមខេត្តនីមួយៗ ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២៣

**ឧបសម្ព័ន្ធទី១៣** : ផែនទីបង្ហាញពីខេត្តដែលបានអនុវត្តកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍ អាល្លឺម៉ង់ ក្នុងឆ្នាំ២០២៣

**ឧបសម្ព័ន្ធទី១៤** : ព័ត៌មានសង្ខេបស្ដីពីចំនួនអតិថិជនដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីជូនអ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២៣ (ខួបឆ្នាំ២០២២)

**ឧបសម្ព័ន្ធទី១៥** : ក្រាភិកបង្ហាញពីអតិថិជនប្រើប្រាស់ថាមពលអគ្គិសនី ដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនី ក្នុងឆ្នាំ២០២៣ (ខួបឆ្នាំ២០២២)

**ឧបសម្ព័ន្ធទី១៦** : ព័ត៌មានសង្ខេបស្ដីពីបរិមាណថាមពលដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីជូនអ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២៣ (ខួបឆ្នាំ២០២២)

**ឧបសម្ព័ន្ធទី១៧** : ក្រាភិកបង្ហាញពីបរិមាណថាមពលដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនី ក្នុងឆ្នាំ២០២៣ (ខួបឆ្នាំ២០២២)

**ឧបសម្ព័ន្ធទី១៨** : ព័ត៌មានសង្ខេបស្ដីពីចំនួនអតិថិជនដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីជូនអ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២៣ (ខួបឆ្នាំ២០២៣)

**ឧបសម្ព័ន្ធទី១៩** : ក្រាភិកបង្ហាញពីអតិថិជនប្រើប្រាស់ថាមពលអគ្គិសនី ដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនី ក្នុងឆ្នាំ២០២៣ (ខួបឆ្នាំ២០២៣)

**ឧបសម្ព័ន្ធទី២០** : ព័ត៌មានសង្ខេបស្ដីពីបរិមាណថាមពលដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីជូនអ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២៣ (ខួបឆ្នាំ២០២៣)

**ឧបសម្ព័ន្ធទី២១** : ក្រាភិកបង្ហាញពីបរិមាណថាមពលដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនី ក្នុងឆ្នាំ២០២៣ (ខួបឆ្នាំ២០២៣)

**ឧបសម្ព័ន្ធទី២២** : ព័ត៌មានសង្ខេបស្ដីពីអតិថិជនបានតភ្ជាប់ចរន្តប្រភេទកសិកម្ម និងទីតាំងធ្វើកសិកម្មតាមខេត្តនីមួយៗ ដែលមានតម្លៃអនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ក្រោមតំបន់អគ្គិសនីកម្ពុជា ក្នុងឆ្នាំ២០២៣

**ឧបសម្ព័ន្ធទី២៣** : ព័ត៌មានសង្ខេបស្ដីពីអ្នកកាន់អាជ្ញាបណ្ណបានតភ្ជាប់ចរន្តប្រភេទកសិកម្ម និងទីតាំងធ្វើកសិកម្មតាមខេត្តនីមួយៗ ដែលមានតម្លៃអនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ក្រោមតំបន់អ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២៣

**ឧបសម្ព័ន្ធទី២៤** : ព័ត៌មានសង្ខេបស្ដីពីអ្នកកាន់អាជ្ញាបណ្ណ និងចំនួននាឡិកាស្ទង់កត់ត្រាលេខអំណានតាមពេលនិងបង់ប្រាក់មុន ដែលបានដំឡើងតាមខេត្តនីមួយៗ ក្រោមតំបន់អ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២៣

# បញ្ជីតារាង


**តារាងទី១** : ព័ត៌មានស្តីពីចំនួនគ្រួសារជនបទគ្រោងតភ្ជាប់ចរន្តអគ្គិសនីជាប់កិច្ចសន្យា (២០២២-២០២៣) ចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តថ្មីតាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្តល់សម្ភារអគ្គិសនីជាអំណោយ ក្នុង១ខ្នងផ្ទះ ក្នុងឆ្នាំ២០២៣

**តារាងទី២** : ចំនួនភូមិសរុប និងចំនួនភូមិបានទទួលការផ្គត់ផ្គង់អគ្គិសនីតាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្តល់សម្ភារអគ្គិសនីជាអំណោយ ក្នុង១ខ្នងផ្ទះ ក្នុងឆ្នាំ២០២៣

**តារាងទី៣** : ព័ត៌មានស្តីពីប្រព័ន្ធសូឡាដែលបានដំឡើងជូនគ្រួសារជនបទតាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្នុងឆ្នាំ២០២៣

**តារាងទី៤** : ចំនួនភូមិសរុប និងចំនួនភូមិបានដំឡើងប្រព័ន្ធសូឡា តាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្នុងឆ្នាំ២០២៣

**តារាងទី៥** : ព័ត៌មានសង្ខេបស្តីពីប្រវែងខ្សែបណ្តាញគ្រោងសាងសង់ជាប់កិច្ចសន្យា ប្រវែងខ្សែបណ្តាញបានសាងសង់រួចតាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីជួយទុនពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២៣

**តារាងទី៦** : ចំនួនភូមិសរុប និងចំនួនភូមិបានទទួលការផ្គត់ផ្គង់អគ្គិសនីតាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២៣

**តារាងទី៧** : ព័ត៌មានសង្ខេបស្តីពីអគ្គិសនីកម្ពុជា បានតភ្ជាប់ចរន្តដល់អ្នកប្រើប្រាស់គ្រប់ប្រភេទ ក្នុងវិស័យកសិកម្មដែលមានតម្លៃអនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ក្រោមតំបន់របស់អគ្គិសនីកម្ពុជា ក្នុងឆ្នាំ២០២៣

**តារាងទី៨** : ព័ត៌មានសង្ខេបស្តីពីអ្នកកាន់អាជ្ញាបណ្ណឯកជនបានតភ្ជាប់ចរន្តដល់អ្នកប្រើប្រាស់គ្រប់ប្រភេទក្នុងវិស័យកសិកម្មដែលមានតម្លៃអនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ក្រោមតំបន់អ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២៣

**តារាងទី៩** : ព័ត៌មានសង្ខេបស្តីពីនាឡិកាស្ទង់កត់ត្រាលេខអំណានតាមពេលនិងបង់ប្រាក់មុន និងស្ថានភាពបច្ចុប្បន្នដែលបានដំឡើងតាមខេត្តនីមួយៗ ក្រោមតំបន់អ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២៣

**តារាងទី១០** : ចំនួនភូមិសរុប និងចំនួនភូមិបានដំឡើងនាឡិកាស្ទង់កត់ត្រាលេខអំណានតាមពេលនិងបង់ប្រាក់មុន តាមខេត្តនីមួយៗ ក្នុងឆ្នាំ២០២៣

# វឌ្ឍនភាព, សមិទ្ធិផល
# និងការវិភាគ នៃកម្មវិធី នាយកដ្ឋាន ម.អ.ជ.

## ១.១ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ

ក្រោមកម្មវិធីនេះ ម.អ.ជ. បន្តអនុវត្តកិច្ចសន្យាចំនួន៦ សល់ពីឆ្នាំ២០២២ ដែល ម.អ.ជ. បានចុះជាមួយអ្នកកាន់អាជ្ញាបណ្ណចំនួន៦ សម្រាប់ផ្តល់សម្ភារអគ្គិសនីជាអំណោយជូនគ្រួសារជនបទ ដើម្បីតភ្ជាប់ចរន្តដល់ផ្ទះគ្រួសារជនបទ។ ក្នុងឆ្នាំ២០២៣ ម.អ.ជ. បានចុះកិច្ចសន្យាចំនួន១២ ជាមួយអ្នកកាន់អាជ្ញាបណ្ណចំនួន១១ (អ្នកកាន់អាជ្ញាបណ្ណចំនួន១ បានអនុវត្តកិច្ចសន្យាចំនួន២) សម្រាប់ផ្តល់សម្ភារអគ្គិសនី ជាអំណោយជូនគ្រួសារជនបទ ដើម្បីតភ្ជាប់ចរន្តដល់ផ្ទះគ្រួសារជនបទ។

ក្នុងចំណោមកិច្ចសន្យាដែលបានចុះហត្ថលេខាចំនួន ១៨កិច្ចសន្យាខាងលើ មានកិច្ចសន្យាចំនួន១៧ បានចុះហត្ថលេខាជាមួយអ្នកកាន់អាជ្ញាបណ្ណចំនួន១៤ ដែលមានចំនួនគ្រួសារជនបទគ្រោងតភ្ជាប់ចរន្តអគ្គិសនីជាប់កិច្ចសន្យាចំនួន ៣.១០៥ខ្នងផ្ទះ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងមានកិច្ចសន្យាចំនួន១ បានចុះហត្ថលេខាជាមួយអ្នកកាន់អាជ្ញាបណ្ណចំនួន១ ដែលមានចំនួនគ្រួសារជនបទគ្រោងតភ្ជាប់ចរន្តអគ្គិសនីជាប់កិច្ចសន្យាចំនួន ១៥០ ខ្នងផ្ទះ ក្រោមថវិកាផ្តល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់។ គ្រួសារជនបទគ្រោងតភ្ជាប់ចរន្តអគ្គិសនី ក្រោមកិច្ចសន្យាចំនួន ១៨កិច្ចសន្យានេះ មានចំនួន ៣.២៥៥ខ្នងផ្ទះ និងគ្រួសារជនបទចំនួន ១.៨៤៨ខ្នងផ្ទះ បានទទួលការតភ្ជាប់ចរន្តរួចក្នុងឆ្នាំ២០២៣ រួមមានក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជាមានចំនួន ១.៦៩៨គ្រួសារ និងក្រោមថវិកាផ្តល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់មានចំនួន ១៥០គ្រួសារ។

ក្នុងចំណោមកិច្ចសន្យាទាំង១៨ខាងលើ កិច្ចសន្យាចំនួន១២ បានអនុវត្តទទួលបានជោគជ័យ ១០០% ក្នុងរយៈពេលកិច្ចសន្យានៃកិច្ចសន្យា ចំណែកកិច្ចសន្យាចំនួន៦ បន្តអនុវត្តនៅឆ្នាំ២០២៤។

**តារាងទី១៖ ព័ត៌មានស្តីពីចំនួនគ្រួសារជនបទគ្រោងតភ្ជាប់ចរន្តអគ្គិសនីជាប់កិច្ចសន្យា (ឆ្នាំ២០២២-២០២៣) ចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តថ្មីតាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្តល់សម្ភារអគ្គិសនីជាអំណោយ ក្នុង១ខ្នងផ្ទះ ក្នុងឆ្នាំ២០២៣**

| ល.រ | ខេត្ត | ចំនួនគ្រួសារជនបទគ្រោងតភ្ជាប់ចរន្ត អគ្គិសនីជាប់កិច្ចសន្យា (គ្រួសារ) | | ចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តថ្មី (គ្រួសារ) |
|---|---|---|---|---|
| | | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | |
| **I ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា** | | | | |
| ១ | បាត់ដំបង | - | ៧២ | ៧២ |
| ២ | កំពង់ធំ | ៤៣៥ | ៥៦៤ | ៧៣៥ |
| ៣ | កណ្តាល | - | ៨៤ | ៨៤ |
| ៤ | ក្រចេះ | - | ៣០០ | - |
| ៥ | ព្រះវិហារ | - | ១៥០ | - |
| ៦ | ពោធិ៍សាត់ | - | ៤៦៧ | ១៧ |
| ៧ | រតនគិរី | ១២៧ | - | ១២៧ |
| ៨ | សៀមរាប | ២២០ | ៨៧ | ៣០៧ |
| ៩ | តាកែវ | ៣០០ | ៥៦ | ៣៥៦ |
| សរុប I | | ១.០៨២ | ២.០២៣ | ១.៦៩៨ |

| II ក្រោមថវិកាផ្ដល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ | | | | |
|---|---|---|---|---|
| ១ | កំពង់ធំ | ១៥០ | - | ១៥០ |
| **សរុប II** | | **១៥០** | **-** | **១៥០** |
| **សរុប I+II** | | **១.២៣២** | **២.០២៣** | **១.៨៤៨** |
| | | **៣.២៥៥** | | |

ក្នុងឆ្នាំ២០២៣ គ្រួសារជនបទបានទទួលផលដោយផ្ទាល់ក្រោមកម្មវិធីនេះ ចំនួន ១.៨៤៨គ្រួសារ។ តាមរបាយការណ៍ចុងក្រោយស្ដីពីអង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣ ចំនួនមនុស្សក្នុង ១គ្រួសារ នៅជនបទជាមធ្យមគឺ ៤,៦នាក់ ដូច្នេះប្រជាជនបានទទួលផលដោយផ្ទាល់ពីកម្មវិធីនេះ គឺចំនួន ៨.៥០០នាក់។

កម្មវិធីផ្ដល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្ដល់សម្ភារអគ្គិសនីជាអំណោយ ក្នុង១ខ្នងផ្ទះនេះ ផ្ដល់នូវកម្លាំងរុញច្រានយ៉ាងខ្លាំងដល់គ្រួសារជនបទបានទទួលចរន្តអគ្គិសនីប្រើប្រាស់។

**តារាងទី២៖ ចំនួនភូមិសរុប និងចំនួនភូមិបានទទួលការផ្គត់ផ្គង់អគ្គិសនីតាមខេត្តនីមួយៗ ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីផ្ដល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្ដល់សម្ភារអគ្គិសនីជាអំណោយ ក្នុង១ខ្នងផ្ទះ ក្នុងឆ្នាំ២០២៣**

| ល.រ | ខេត្ត | ចំនួនភូមិសរុប (ជំរឿន) | ចំនួនភូមិគ្របដណ្ដប់ | |
|---|---|---|---|---|
| | | | ថវិកាផ្ដល់ដោយ អគ្គិសនីកម្ពុជា | ថវិកាផ្ដល់ដោយ ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ |
| ១ | បាត់ដំបង | ៨០៥ | ៧ | - |
| ២ | កំពង់ធំ | ៧៤២ | ៣១ | ២៣ |
| ៣ | កំពត | ៤៨៨ | ១០ | - |
| ៤ | កណ្ដាល | ៩១៨ | ១២ | - |
| ៥ | ពោធិ៍សាត់ | ៥១០ | ១ | - |
| ៦ | រតនគិរី | ២៤៣ | ១៥ | - |
| ៧ | សៀមរាប | ៩៣០ | ២០ | - |
| ៨ | តាកែវ | ១.១១៩ | ៧២ | - |
| **សរុប** | | **៤.៦៣៧** | **១៦៨** | **២៣** |
| **សរុបរួម** | | | **១៩១** | |

ព័ត៌មានលម្អិតអំពី ការចុះកិច្ចសន្យា ចំនួននៃការតភ្ជាប់តាមខេត្ត និងភូមិគ្របដណ្ដប់ មានបង្ហាញជូនក្នុងឧបសម្ព័ន្ធដូចខាងក្រោម៖

- **ឧបសម្ព័ន្ធទី៤** ព័ត៌មានលម្អិតស្ដីពីកិច្ចសន្យាដែល ម.អ.ជ. បានចុះហត្ថលេខាជាមួយសេវាករ។
- **ឧបសម្ព័ន្ធទី៥** ព័ត៌មានលម្អិតស្ដីពីចំនួនគ្រួសារជនបទជាប់កិច្ចសន្យា ចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តថ្មី និងស្ថានភាពបច្ចុប្បន្ន ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់។
- **ឧបសម្ព័ន្ធទី៦** បញ្ជីឈ្មោះភូមិដែលគ្របដណ្ដប់តាមខេត្តនីមួយៗ។
- **ឧបសម្ព័ន្ធទី៧** ផែនទីបង្ហាញ ពីខេត្តដែលបានអនុវត្តកម្មវិធីនេះ។

**សកម្មភាពចុះពិនិត្យការអនុវត្តកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ**

ដើម្បីធានាថា ការអនុវត្តកម្មវិធីនេះ ឱ្យប្រព្រឹត្តទៅប្រកបដោយតម្លាភាព និងត្រឹមត្រូវ និយោជិត ម.អ.ជ. បានចុះផ្ទៀងផ្ទាត់ការតភ្ជាប់ចរន្តអគ្គិសនីថ្មីដល់គ្រួសារជនបទគ្រប់សេវាករដែលបានអនុវត្តកម្មវិធីនេះ។ រូបភាពសកម្មភាព មួយចំនួនស្តីពីការចុះផ្ទៀងផ្ទាត់ការតភ្ជាប់ចរន្តអគ្គិសនីថ្មីដល់គ្រួសារជនបទ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្តល់សម្ភារអគ្គិសនីជាអំណោយ ក្នុង១ខ្នងផ្ទះ មានបង្ហាញខាងក្រោម។

**លោក វង្ស សំបូរ អាជ្ញាបណ្ណលេខ ២៨១អ ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃឃុំប្រម៉ោយ និងឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់**






## ១.២ កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ (SHS)

ក្នុងការអនុវត្តកម្មវិធីនេះ ម.អ.ជ. មានក្រុមហ៊ុនឯកជនចំនួន២ សម្រាប់ផ្តល់សេវាកម្ម រួមមាន៖ ១- ក្រុមហ៊ុន ផ្គត់ផ្គង់សម្ភារប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ និង ២- ក្រុមហ៊ុនផ្តល់សេវាកម្មដឹកជញ្ជូន និងដំឡើងប្រព័ន្ធថាមពល ពន្លឺព្រះអាទិត្យតាមផ្ទះ។

វឌ្ឍនភាព សមិទ្ធផល និងការវិភាគពីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ ក្នុងឆ្នាំ២០២៣ មានដូចខាងក្រោម៖

១. **ប្រព័ន្ធ SHS-៥០០វ៉ាត់ មានថ្មផ្ទាំងដាំបាយអគ្គិសនីប្រភេទ Panasonic ចំណុះ ៤លីត្រ៖** ម.អ.ជ. បានផ្គត់ផ្គង់សម្ភារ និងដំឡើងប្រព័ន្ធ SHS-៥០០វ៉ាត់ មានឆ្នាំងដាំបាយអគ្គិសនីប្រភេទ Panasonic ចំណុះ ៤លីត្រ ចំនួន ១.០៣៧កំប្លេរ ជាអំណោយជូនគ្រួសារជនបទ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា។ ក្នុងឃ្លាំងអគ្គិសនីកម្ពុជា មានប្រព័ន្ធ SHS-៥០០វ៉ាត់ មានឆ្នាំងដាំបាយអគ្គិសនីប្រភេទ Panasonic ចំណុះ ៤លីត្រ សល់ពីកម្មវិធីប្រព័ន្ធ SHS មុនៗ។ គិតត្រឹមចុងឆ្នាំ២០២៣ ម.អ.ជ. មាននៅសល់

ប្រព័ន្ធ SHS-៥០០វ៉ាត់ មានថ្មផ្ទាំងដាំបាយអគ្គិសនីប្រភេទ Panasonic ចំណុះ ៥លីត្រ ចំនួន ១.៨០១ កំប្លេរ សម្រាប់ផ្តល់ជាអំណោយជូនគ្រួសារជនបទ ក្នុងឆ្នាំ២០២៤។

២. **ប្រព័ន្ធ SHS-៥០វ៉ាត់៖** ម.អ.ជ. បានផ្គត់ផ្គង់សម្ភារ និងដំឡើងប្រព័ន្ធ SHS-៥០វ៉ាត់ ចំនួន ៦៨៥កំប្លេរ ជាអំណោយជូនគ្រួសារជនបទ ក្រោមថវិកាផ្តល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់។

៣. **ប្រព័ន្ធសូឡា អានុភាព ៣,៥គីឡូវ៉ាត់ ចំនួន ១កំប្លេរ៖** ម.អ.ជ. បានផ្គត់ផ្គង់សម្ភារ និងដំឡើងប្រព័ន្ធសូឡា អានុភាព ៣,៥គីឡូវ៉ាត់ ចំនួន ១កំប្លេរ ជាអំណោយជូនទីបញ្ជាការស្រោលសម្រាប់បង្ក្រាបបទល្មើស នេសាទស្ថិតនៅចំណុចពាក់កន្ទេល ភូមិព្រែកទាល់ ឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា។

៤. **ប្រព័ន្ធសូឡាបំភ្លឺផ្លូវសាធារណៈ អានុភាព ១០០វ៉ាត់ ចំនួន ១៧០កំប្លេរ៖** ម.អ.ជ. បានផ្គត់ផ្គង់សម្ភារ និងដំឡើងប្រព័ន្ធសូឡាបំភ្លឺផ្លូវសាធារណៈ អានុភាព ១០០វ៉ាត់ ចំនួន ១៧០កំប្លេរ ជាអំណោយជូនរដ្ឋបាលខេត្តបាត់ដំបង សម្រាប់បំភ្លឺផ្លូវសាធារណៈនៅសង្កាត់អូរចារ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា។

៥. **ប្រព័ន្ធសូឡាបំភ្លឺបរិវេណទីបញ្ជាការជួរមុខ អានុភាព ១០០វ៉ាត់ ចំនួន ១៦កំប្លេរ៖** ម.អ.ជ. បានផ្គត់ផ្គង់សម្ភារ និងដំឡើងប្រព័ន្ធសូឡា អានុភាព ១០០វ៉ាត់ ចំនួន ១៦កំប្លេរ ជាអំណោយជូនទីបញ្ជាការជួរមុខ សម្រាប់បំភ្លឺបរិវេណទីបញ្ជាការ ស្ថិតនៅទំនប់កោះព្រាប ភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា។

៦. **អាគុយសូឡា ចំនួន ៤គ្រាប់៖** ម.អ.ជ. បានផ្គត់ផ្គង់សម្ភារ និងដំឡើងអាគុយសូឡាចំនួន ៤គ្រាប់ ជាអំណោយជូនមណ្ឌលផ្ទះស្វែងរកក្តីស្រម៉ៃឱ្យកុមារស្ថិតនៅភូមិប៉ប៉ិត ឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា។

៧. **ប្រព័ន្ធសូឡាបំភ្លឺបរិវេណកងពលតូចអន្តរាគមន៍លេខ១៤ អានុភាព ៨០វ៉ាត់ ចំនួន ៦កំប្លេរ៖** ម.អ.ជ. បានផ្គត់ផ្គង់សម្ភារ និងដំឡើងប្រព័ន្ធសូឡា អានុភាព ៨០វ៉ាត់ ចំនួន ១៦កំប្លេរ ជាអំណោយជូនកងពលតូចអន្តរាគមន៍លេខ១៤ សម្រាប់បំភ្លឺបរិវេណកងពលតូចអន្តរាគមន៍លេខ១៤ ស្ថិតនៅភូមិឈើទាល ឃុំត្នោតជុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា។

៨. **ប្រព័ន្ធសូឡាបូមទឹក អានុភាព ៣,៥៦គីឡូវ៉ាត់ រួមទាំងសម្ភារមួយចំនួន ដូចជាម៉ូទ័រ បូមទឹក ទុយយោទឹក និងធុងស្តុកទឹក៖** ម.អ.ជ. បានផ្គត់ផ្គង់សម្ភារ និងដំឡើងប្រព័ន្ធសូឡាបូមទឹក អានុភាព ៣,៥៦គីឡូវ៉ាត់ រួមទាំងសម្ភារមួយចំនួន ដូចជាម៉ូទ័របូមទឹក ទុយយោទឹក និងធុងស្តុកទឹក សម្រាប់បូមទឹក បញ្ជូនទឹកស្តុកទឹកលើភ្នំ ជាអំណោយជូនកងទ័ពឈរជើងជួរមុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ (ទិសប្រាសាទតាមាន់) នៃយោធភូមិភាគទី៤ កងពលតូចថ្មើរជើងលេខ៤២ ខេត្តឧត្តរមានជ័យ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា។

**តារាងទី៣៖ ព័ត៌មានស្តីពីប្រព័ន្ធសូឡាដែលបានដំឡើងនៅតំបន់ជនបទតាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្នុងឆ្នាំ២០២៣**

| ល.រ | ខេត្ត | ចំនួនប្រព័ន្ធដែលបានដំឡើង |
|---|---|---|
| **ក** | **ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា** | |
| ១ | បាត់ដំបង | ១៧១ |
| ២ | ពោធិ៍សាត់ | ១.០៤៧ |

| | | |
|---|---|---|
| ៣ | ព្រះសីហនុ | ១៦ |
| ៤ | ឧត្ដរមានជ័យ | ៣ |
| **សរុប** | | ១.២៣៧ |
| **ខ ក្រោមថវិកាផ្ដល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់** | | |
| ១ | ពោធិ៍សាត់ | ៦៨៥ |
| **សរុប** | | **៦៨៥** |
| **សរុបរួម** | | **១.៩២២** |

គ្រួសារជនបទបានទទួលផលដោយផ្ទាល់ពីកម្មវិធីនេះ ចំនួន ១.៩២២គ្រួសារ (១គ្រួសារ១ប្រព័ន្ធ)។ តាមរបាយការណ៍ចុងក្រោយស្ដីពីអង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣ ចំនួនមនុស្សក្នុង១គ្រួសារនៅជនបទជាមធ្យមគឺ ៤,៦នាក់ ដូច្នេះប្រជាជនបានទទួលផលដោយផ្ទាល់ពីកម្មវិធីនេះ គឺ ៨.៨៤១នាក់។

**តារាងទី៤៖ ចំនួនភូមិសរុប និងចំនួនភូមិបានដំឡើងប្រព័ន្ធសូឡាតាមខេត្តនីមួយៗ ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្នុងឆ្នាំ២០២៣**

| ល.រ | ខេត្ត | ចំនួនភូមិសរុប (ជំរឿន) | ចំនួនភូមិបានដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ | |
|---|---|---|---|---|
| | | | ថវិកាអគ្គិសនីកម្ពុជា | ក្រោមថវិកាផ្ដល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ |
| ១ | បាត់ដំបង | ៨០៥ | ៤ | - |
| ២ | ពោធិ៍សាត់ | ៥១០ | ២៩ | ៣ |
| ៣ | ព្រះសីហនុ | ១១៥ | ១ | - |
| ៤ | ឧត្ដរមានជ័យ | ២៦០ | ១ | - |
| **សរុប** | | **១.៦៩០** | **៣៥** | **៣** |

ព័ត៌មានលម្អិតអំពីបញ្ជីឈ្មោះភូមិ និងផែនទីបង្ហាញពីខេត្ត ដែល ម.អ.ជ. បានដំឡើងប្រព័ន្ធសូឡា មានបង្ហាញជូនក្នុងឧបសម្ព័ន្ធដូចខាងក្រោម៖

- **ឧបសម្ព័ន្ធទី៨** បង្ហាញពីបញ្ជីឈ្មោះភូមិដែល ម.អ.ជ. បានដំឡើងប្រព័ន្ធសូឡា ក្នុងឆ្នាំ២០២៣។
- **ឧបសម្ព័ន្ធទី៩** ផែនទីបង្ហាញពីខេត្ត បានដំឡើងប្រព័ន្ធសូឡា ក្នុងឆ្នាំ២០២៣។

## ១.៣ កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ

### វឌ្ឍនភាព សមិទ្ធផល និងការវិភាគពីកម្មវិធី

ក្នុងឆ្នាំ២០២៣ ម.អ.ជ. បានចុះកិច្ចសន្យាចំនួន៣១ ជាមួយអ្នកកាន់អាជ្ញាបណ្ណចំនួន៣១ សម្រាប់ជួយទុនពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ។ ក្នុងចំណោមកិច្ចសន្យាដែលបានចុះហត្ថលេខាទាំងនេះ មានកិច្ចសន្យាចំនួន១៥ បានចុះហត្ថលេខាជាមួយអ្នកកាន់អាជ្ញាបណ្ណចំនួន១៥ ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា និងកិច្ចសន្យាចំនួន១៦ បានចុះហត្ថលេខាជាមួយអ្នកកាន់អាជ្ញាបណ្ណចំនួន១៦ ក្រោមថវិកាផ្ដល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់។

ក្នុងចំណោមកិច្ចសន្យាខាងលើ កិច្ចសន្យាចំនួន២៩ បានអនុវត្តទទួលបានជោគជ័យ ១០០% ក្នុងរយៈពេលនៃកិច្ចសន្យា ចំណែកកិច្ចសន្យាចំនួន២ បន្តអនុវត្តនៅឆ្នាំ២០២៤។

តារាងទី៥៖ ព័ត៌មានសង្ខេបស្តីពីប្រវែងខ្សែបណ្តាញគ្រោងសាងសង់ជាប់កិច្ចសន្យា ប្រវែងខ្សែបណ្តាញបានសាងសង់រួចតាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីជួយទុនពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២៣

| ល.រ | ខេត្ត | ប្រវែងខ្សែបណ្តាញជាប់កិច្ចសន្យា (គីឡូម៉ែត) | | ប្រវែងខ្សែបណ្តាញបានសាងសង់រួច (គីឡូម៉ែត) | |
|---|---|---|---|---|---|
| | | តង់ស្យុងទាប | តង់ស្យុងមធ្យម | តង់ស្យុងទាប | តង់ស្យុងមធ្យម |
| **ក ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា** | | | | | |
| ១ | បន្ទាយមានជ័យ | ១៣,៣០ | ២៦,៧០ | ១៣,៣០ | ២៦,៧០ |
| ២ | កំពង់ចាម | ១,៩០ | ២,១០ | - | - |
| ៣ | កំពង់ស្ពឺ | ៤,០០ | ៣២,៩០ | ៤,០០ | ៣២,៩០ |
| ៤ | ក្រចេះ | ២៣,៥៣ | ១១,១៥ | ២៣,៥៣ | ១១,១៥ |
| ៥ | ព្រះវិហារ | ១២,៥០ | ១០,៦០ | ១២,៥០ | ១០,៦០ |
| ៦ | ពោធិ៍សាត់ | ៥៥,៨០ | ២៦,៧០ | ៥៣,២០ | ៩,៤០ |
| ៧ | រតនគីរី | ៣,៦០ | ១៦,១៤ | ៣,៦០ | ១៦,១៤ |
| ៨ | សៀមរាប | ៣៦,៥០ | ៤១,១០ | ៣៦,៥០ | ៤១,១០ |
| ៩ | តាកែវ | ២១,២៥ | ១៦,៤០ | ២១,២៥ | ១៦,៤០ |
| **សរុប ក** | | **១៧២,៣៨** | **១៨៣,៧៩** | **១៦៧,៨៨** | **១៦៤,៣៩** |
| | | **៣៥៦,១៧** | | **៣៣២,២៧** | |
| **ខ ក្រោមថវិកាផ្តល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់** | | | | | |
| ១ | បន្ទាយមានជ័យ | ៦,០០ | ៨,៥០ | ៦,០០ | ៨,៥០ |
| ២ | បាត់ដំបង | ១២,១០ | ៨,៣០ | ១២,១០ | ៨,៣០ |
| ៣ | កំពង់ឆ្នាំង | ២០,៨០ | ១៥,០០ | ២០,៨០ | ១៥,០០ |
| ៤ | កំពង់ធំ | ១៤,២០ | ១២,២១ | ១៤,២០ | ១២,២១ |
| ៥ | ព្រះវិហារ | ១៣,៦៤ | ២,០០ | ៩,១០ | - |
| ៦ | ព្រៃវែង | ២២,៨១ | ១៤,០០ | ២០,៨០ | ១៣,៥០ |
| ៧ | ពោធិ៍សាត់ | ២៧,១០ | ៧,៣០ | ១២,០០ | - |
| ៨ | សៀមរាប | ១៨,៨០ | ១៥,២០ | ១៨,៨០ | ១៥,២០ |
| ៩ | ស្វាយរៀង | ១២,០០ | ២៦,៧១ | ១២,០០ | ២២,៦៧ |
| **សរុប ខ** | | **១៤៧,៤៥** | **១០៩,២២** | **១២៥,៨០** | **៩៥,៣៨** |
| | | **២៥៦,៦៧** | | **២២១,១៨** | |
| **សរុប ក+ខ** | | **៣១៩,៨៣** | **២៩៣,០១** | **២៩៣,៦៨** | **២៥៩,៧៧** |
| | | **៦១២,៨៤** | | **៥៥៣,៤៥** | |

ក្នុងឆ្នាំ២០២៣ អ្នកកាន់អាជ្ញាបណ្ណបានទទួលផលដោយផ្ទាល់ក្រោមកម្មវិធីនេះ មានចំនួន៣៥។

កម្មវិធីនេះបានផ្តល់នូវកម្លាំងរុញច្រានយ៉ាងខ្លាំងដល់សហគ្រាសអគ្គិសនីជនបទ ក្នុងការពង្រីកវិសាលភាពផ្គត់ផ្គង់អគ្គិសនីក្នុងតំបន់អាជ្ញាបណ្ណរបស់ខ្លួនឱ្យបានពេញលឿន និងគ្រួសារជនបទកាន់តែច្រើនគ្រួសារអាចទទួលបាននូវសេវាកម្មផ្គត់ផ្គង់អគ្គិសនី ដែលមានគុណភាពពីប្រព័ន្ធបណ្តាញសហគ្រាសអគ្គិសនីជនបទ។

**តារាងទី៦៖ ចំនួនភូមិសរុប និងចំនួនភូមិបានទទួលការផ្គត់ផ្គង់អគ្គិសនីតាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអេភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីជួយទុនពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២៣**

| ល.រ | ខេត្ត | ចំនួនភូមិសរុប (ជំរឿន) | ចំនួនភូមិគ្របដណ្តប់ | |
|---|---|---|---|---|
| | | | ថវិកាផ្តល់ដោយ អគ្គិសនីកម្ពុជា | ថវិកាផ្តល់ដោយ ធនាគារអេភិវឌ្ឍន៍អាល្លឺម៉ង់ |
| ១ | បន្ទាយមានជ័យ | ៦៦១ | ១២ | ៦ |
| ២ | បាត់ដំបង | ៨០៥ | - | ៥ |
| ៣ | កំពង់ចាម | ៩១៦ | - | ១ |
| ៤ | កំពង់ឆ្នាំង | ៥៦៨ | - | ៤ |
| ៥ | កំពង់ស្ពឺ | ១.៣៦២ | ១៣ | - |
| ៦ | កំពង់ធំ | ៧៤២ | - | ១៤ |
| ៧ | កំពត | ៤៨៨ | ២ | - |
| ៨ | កោះកុង | ១១៧ | - | ៧ |
| ៩ | ក្រចេះ | ២៥៣ | ១១ | - |
| ១០ | ព្រះវិហារ | ២៣២ | ១៤ | - |
| ១១ | ព្រៃវែង | ១.១៣៧ | - | ៦ |
| ១២ | ពោធិ៍សាត់ | ៥១០ | ៣២ | ៦ |
| ១៣ | រតនគិរី | ២៤៣ | ៦ | - |
| ១៤ | សៀមរាប | ៩៣០ | ១០ | ៦ |
| ១៥ | ស្វាយរៀង | ៦៩០ | - | ១៤ |
| ១៦ | តាកែវ | ១.១១៩ | ១៥ | - |
| ១៧ | ត្បូងឃ្មុំ | ៨៥៣ | ៦ | - |
| **សរុប** | | **១១.៦២៦** | **១២១** | **៦៩** |
| **សរុបរួម** | | | **១៩០** | |

ព័ត៌មានលម្អិតស្តីពីការចុះកិច្ចសន្យា ប្រវែងខ្សែបណ្តាញគ្រោងសាងសង់ជាប់កិច្ចសន្យា ប្រវែងខ្សែបណ្តាញបានសាងសង់រួច ស្ថានភាពបច្ចុប្បន្ន និងភូមិដែលគ្របដណ្តប់តាមខេត្តនីមួយៗ មានបង្ហាញជូនក្នុងឧបសម្ព័ន្ធដូចខាងក្រោម៖

- **ឧបសម្ព័ន្ធទី១០** បង្ហាញពីព័ត៌មានចុះកិច្ចសន្យាតាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអេភិវឌ្ឍន៍អាល្លឺម៉ង់ ក្នុងឆ្នាំ២០២៣។
- **ឧបសម្ព័ន្ធទី១១** បង្ហាញពីព័ត៌មានប្រវែងខ្សែបណ្តាញគ្រោងសាងសង់ជាប់កិច្ចសន្យា ប្រវែងខ្សែបណ្តាញបានសាងសង់រួចនិងស្ថានភាពបច្ចុប្បន្នតាមខេត្តនីមួយៗ។
- **ឧបសម្ព័ន្ធទី១២** បង្ហាញពីបញ្ជីឈ្មោះភូមិដែលគ្របដណ្តប់តាមខេត្តនីមួយៗ។
- **ឧបសម្ព័ន្ធទី១៣** ផែនទីបង្ហាញពីខេត្តដែលបានអនុវត្តកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២៣។

**សកម្មភាពចុះពិនិត្យការអនុវត្តកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ**

ដើម្បីធានាថា ការអនុវត្តកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ប្រព្រឹត្តទៅត្រឹមត្រូវ និងប្រកបដោយតម្លាភាព និយោជិត ម.អ.ជ. បានចុះផ្ទៀងផ្ទាត់ការសាងសង់គ្រប់សេវាករ ដែលបានអនុវត្តកម្មវិធីនេះ។ រូបភាពសកម្មមួយចំនួនស្ដីពីការចុះផ្ទៀងផ្ទាត់ខ្សែបណ្ដាញថ្មីក្រោយពេលសាងសង់រួច មានបង្ហាញជូនខាងក្រោម។

**ក្រុមហ៊ុន អគ្គិសនី បឹងកន្ទួត កាន់អាជ្ញាបណ្ណលេខ ៥០១អ ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកក្រគរ និងឃុំកញ្ជរ ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់**



## ១.៤ កម្មវិធីផ្ដល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណ ធ្វើអាជីវកម្មអគ្គិសនីដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយប្រព័ន្ធបណ្ដាញជាតិ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទ ក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងតម្លាតថ្លៃលក់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២៣ តាមបណ្ដាខេត្ត និងរាជធានី

ក្នុងឆ្នាំ២០២៣ ម.អ.ជ. ផ្ដល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទ និងអាជីវករលក់ដូរនៅផ្សារ ដូចខាងក្រោម៖

១. ចំនួន ៣២៥តំបន់អាជ្ញាបណ្ណទូទាំងប្រទេស។

២. អ្នកកាន់អាជ្ញាបណ្ណធ្វើសេវាកម្មអគ្គិសនីនៅក្នុងបរិវេណផ្សារចំនួន ៦៥តំបន់ផ្សារ។

ព័ត៌មានលម្អិតអំពីកម្មវិធីឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីមានបង្ហាញជូនក្នុងឧបសម្ព័ន្ធដូចខាងក្រោម៖

- **ឧបសម្ព័ន្ធទី១៤-១៧** សង្ខេបស្ដីពីចំនួនអតិថិជន បរិមាណថាមពល និងក្រាកិកដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីជូនអ្នកកាន់អាជ្ញាបណ្ណតាមខេត្តនីមួយៗ ក្នុងឆ្នាំ ២០២៣ សម្រាប់ខួបឆ្នាំ២០២២។
- **ឧបសម្ព័ន្ធទី១៨-២១** សង្ខេបស្ដីពីចំនួនអតិថិជន បរិមាណថាមពល និងក្រាកិកដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីជូនអ្នកកាន់អាជ្ញាបណ្ណតាមខេត្តនីមួយៗ ក្នុងឆ្នាំ ២០២៣ សម្រាប់ខួបឆ្នាំ២០២៣។

### ១.៥ កម្មវិធីអនុវត្តអត្រាថ្លៃលក់អនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទក្នុងវិស័យកសិកម្មក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនី ដែលទទួលប្រភពពីបណ្ដាញជាតិ

ចាប់ពីឆ្នាំ២០១៦ ក្រសួងរ៉ែ និងថាមពល បានដាក់ចេញនូវគោលនយោបាយផ្ដល់ថ្លៃអនុគ្រោះពិសេសចំពោះអ្នកប្រើប្រាស់ដែលយកអគ្គិសនីទៅបូមទឹកសម្រាប់ការធ្វើកសិកម្មនៅពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ឱ្យបង់ថ្លៃអគ្គិសនីត្រឹមតែ ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោងប៉ុណ្ណោះ។ នៅឆ្នាំ២០២១ ក្រសួងរ៉ែ និងថាមពល បានពង្រីកវិសាលភាពនៃការផ្ដល់ថ្លៃអនុគ្រោះពិសេសនេះ ដល់អ្នកប្រើប្រាស់អគ្គិសនីគ្រប់ប្រភេទក្នុងវិស័យកសិកម្ម។

ក្នុងឆ្នាំ២០២៣ កម្មវិធីនេះបន្តផ្ដល់តម្លៃអនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង ឱ្យអ្នកប្រើប្រាស់អគ្គិសនីគ្រប់ប្រភេទក្នុងវិស័យកសិកម្មទទួលបានតម្លៃអនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីដែលទទួលប្រភពពីបណ្ដាញជាតិ និងនូវតម្លៃធម្មតាសម្រាប់ការប្រើប្រាស់ពេលថ្ងៃ ចាប់ពីម៉ោង ៧:០០ព្រឹក ដល់ម៉ោង ៩:០០យប់។

**តារាងទី៧៖ ព័ត៌មានសង្ខេបស្ដីពីអគ្គិសនីកម្ពុជា បានតភ្ជាប់ចរន្តដល់អ្នកប្រើប្រាស់គ្រប់ប្រភេទក្នុងវិស័យកសិកម្មដែលមានតម្លៃអនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ក្រោមតំបន់អគ្គិសនីកម្ពុជា ក្នុងឆ្នាំ ២០២៣**

| ឆ្នាំ | ចំនួនអតិថិជនបានតភ្ជាប់ចរន្តរួច | |
|---|---|---|
| | អតិថិជនប្ដូរពីប្រភេទផ្សេងៗមកប្រភេទកសិកម្ម | អតិថិជនតភ្ជាប់ចរន្តថ្មី |
| ២០២៣ | ១៣៦ | ២៥ |
| **សរុប** | **១៦១** | |

**តារាងទី៨៖ ព័ត៌មានសង្ខេបស្ដីពីអ្នកកាន់អាជ្ញាបណ្ណបានតភ្ជាប់ចរន្តដល់អ្នកប្រើប្រាស់គ្រប់ប្រភេទក្នុងវិស័យកសិកម្មដែលមានតម្លៃអនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ក្រោមតំបន់អ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២៣**

| ឆ្នាំ | ចំនួនអតិថិជនបានតភ្ជាប់ចរន្តរួច | |
|---|---|---|
| | អតិថិជនប្ដូរពីប្រភេទផ្សេងៗ មកប្រភេទកសិកម្ម | អតិថិជនតភ្ជាប់ចរន្តថ្មី |
| ២០២៣ | ៨៤៥ | ១៥៧ |
| **សរុប** | **១.០០២** | |

កម្មវិធីនេះបានជំរុញយ៉ាងខ្លាំងដល់វិស័យកសិកម្ម ដោយគាំទ្រដល់សកម្មភាពដូចជា ការដាំដុះដំណាំ ការចិញ្ចឹមសត្វ ការធារាសាស្រ្ត វារីវប្បកម្ម ការសម្ងួត ការបង្កក ការផលិតដី ការកិនស្រូវ ការកែច្នៃកំប៉ុង ការកែច្នៃចំណីអាហារ និងភេសជ្ជៈ និងការផលិតចំណីសត្វ។ គ្រួសារជនបទ និងអាជីវកម្មកសិផលជាច្រើនបានទទួលអត្ថប្រយោជន៍ ពីកម្មវិធីនេះ។

ដើម្បីធានាថា ការអនុវត្តកម្មវិធីផ្តល់ថ្លៃអនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង ដល់អ្នកប្រើប្រាស់គ្រប់ប្រភេទក្នុងវិស័យកសិកម្ម សម្រាប់ការប្រើប្រាស់ពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ប្រព្រឹត្តទៅត្រឹមត្រូវ និងប្រកបដោយតម្លាភាព និយោជិត ម.អ.ជ. បានចុះពិនិត្យផ្ទៀងផ្ទាត់ការស្នើសុំគ្រប់អ្នកកាន់អាជ្ញាបណ្ណដែលបានអនុវត្តកម្មវិធីនេះ។ រូបភាពសកម្មភាពមួយចំនួនស្តីពីការចុះពិនិត្យការស្នើសុំអនុវត្តកម្មវិធីផ្តល់ថ្លៃអនុគ្រោះពិសេសរបស់អ្នកកាន់អាជ្ញាបណ្ណមានបង្ហាញជូនដូចខាងក្រោម។

**សហគ្រាស វណ្ណាឡៃហ៊ីម អេឡិកទ្រីស៊ីធី អាជ្ញាបណ្ណលេខ ៣២៦អ ធ្វើសេវាកម្មអគ្គិសនីនៅ**
**ផ្នែកខ្លះនៃស្រុកប្រាសាទសំបូរ និងស្រុកសណ្តាន់ ខេត្តកំពង់ធំ**






ដើម្បីគាំទ្រដល់ការប្រើប្រាស់អគ្គិសនីក្នុងវិស័យកសិកម្មបន្ថែមទៀត នាឡិកាស្ទង់កត់ត្រាលេខអំណានតាមពេលនិងបង់ប្រាក់មុន ត្រូវបានដំឡើងនៅក្រោមតំបន់ផ្គត់ផ្គង់ដែលមានអាជ្ញាប័ណ្ណ។

**តារាងទី៩៖ ព័ត៌មានសង្ខេបស្តីពីនាឡិកាស្ទង់កត់ត្រាលេខអំណានតាមពេលនិងបង់ប្រាក់មុន និងស្ថានភាពបច្ចុប្បន្នដែលបានដំឡើងតាមខេត្តនីមួយៗ ក្រោមតំបន់អ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២៣**

| ល.រ | ខេត្ត | នាឡិកាស្ទង់កត់ត្រាលេខអំណានតាមពេលនិងបង់ប្រាក់មុន (កំប្លេរ) | |
|---|---|---|---|
| | | អ្នកកាន់អាជ្ញាបណ្ណស្នើសុំ | ដំឡើងរួច |
| ១ | ព្រៃវែង | ៩៥ | ៩៥ |

| សរុប | ៩៥ | ៩៥ |
|---|---|---|

តារាងទី១០៖ ចំនួនភូមិសរុប និងចំនួនភូមិបានដំឡើងនាឡិកាស្ទង់កត់ត្រាលេខអំណានតាមពេលនិងបង់ប្រាក់មុន តាមខេត្តនីមួយៗ ក្នុងឆ្នាំ២០២៣

| ល.រ | ខេត្ត | ចំនួនភូមិសរុប (ជំរឿន) | ចំនួនភូមិគ្របដណ្តប់ |
|---|---|---|---|
| ១ | ព្រៃវែង | ១.១៣៧ | ៩ |
| សរុប | | ១.១៣៧ | ៩ |

ដើម្បីធានាថា ការដំឡើងនាឡិកាស្ទង់កត់ត្រាលេខអំណានតាមពេលនិងបង់ប្រាក់មុន ប្រព្រឹត្តទៅត្រឹមត្រូវ និងប្រកបដោយតម្លាភាព និយ័តករ ម.អ.ផ. បានចុះពិនិត្យផ្ទៀងផ្ទាត់ការសាងសង់គ្រប់អ្នកកាន់អាជ្ញាបណ្ណដែលទទួលបានការដំឡើងនាឡិកាស្ទង់កត់ត្រាលេខអំណានតាមពេលនិងបង់ប្រាក់មុននេះ។ រូបភាពសកម្មភាពមួយចំនួនស្តីពីការចុះពិនិត្យការដំឡើងនាឡិកាស្ទង់កត់ត្រាលេខអំណានតាមពេល និងបង់ប្រាក់មុនមានបង្ហាញដូចខាងក្រោម។

**សហគ្រាស ឈរ វែងងួន អេឡិចទ្រីស៊ីធី អេនធើប្រាយ អាជ្ញាបណ្ណលេខ ៣៥៥អ ធ្វើសេវាកម្មអគ្គិសនី នៅផ្នែកខ្លះនៃស្រុកពោធិ៍រៀង ស្រុកពារាំង ខេត្តព្រៃវែង និងស្រុកល្វាឯម ខេត្តកណ្តាល**





ព័ត៌មានលម្អិតស្តីពីអតិថិជនបានតភ្ជាប់ចរន្តប្រភេទកសិកម្ម និងទីតាំងធ្វើកសិកម្ម តាមខេត្តនីមួយៗ ដែលមានតម្លៃអនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ក្នុងឆ្នាំ២០២៣ មានបង្ហាញជូនក្នុងឧបសម្ព័ន្ធដូចខាងក្រោម៖

- **ឧបសម្ព័ន្ធទី២២** បង្ហាញពីព័ត៌មានសង្ខេបស្តីពីអតិថិជនបានតភ្ជាប់ចរន្តប្រភេទកសិកម្ម និងទីតាំងធ្វើកសិកម្ម តាមខេត្តនីមួយៗ ក្រោមតំបន់អគ្គិសនីកម្ពុជា ក្នុងឆ្នាំ២០២៣។
- **ឧបសម្ព័ន្ធទី២៣** បង្ហាញពីព័ត៌មានសង្ខេបស្តីពីអ្នកកាន់អាជ្ញាបណ្ណបានតភ្ជាប់ចរន្តប្រភេទកសិកម្ម និងទីតាំងធ្វើកសិកម្មតាមខេត្តនីមួយៗ ក្រោមតំបន់អ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២៣។
- **ឧបសម្ព័ន្ធទី២៤** ព័ត៌មានសង្ខេបស្តីពីអ្នកកាន់អាជ្ញាបណ្ណ និងចំនួននាឡិកាស្ទង់កត់ត្រាលេខអំណានតាមពេលនិងបង់ប្រាក់មុន ដែលបានដំឡើងតាមខេត្តនីមួយៗ ក្រោមតំបន់អ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២៣។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១
## គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ ថាមពលអគ្គិសនី និងគោលនយោបាយពាក់ព័ន្ធជាមួយការអភិវឌ្ឍតំបន់ជនបទ និងការប្រើប្រាស់ថាមពលកកើតឡើងវិញ

### ១.១ គោលនយោបាយវិស័យថាមពលអគ្គិសនីរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា

ថាមពលអគ្គិសនី គឺជាផលិតផលមួយមានសារៈសំខាន់ណាស់សម្រាប់សង្គម និងសេដ្ឋកិច្ច។ ថាមពលអគ្គិសនីមិនត្រឹមតែជាផលិតផលមួយសម្រាប់បំរើឱ្យជីវភាពរស់នៅប៉ុណ្ណោះទេ តែក៏ជាផលិតផលមួយចាំបាច់សម្រាប់ជំរុញការអភិវឌ្ឍវិស័យផ្សេងៗទៀតរបស់ប្រទេសជាតិផងដែរ។ ដូច្នេះ ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី គឺជាគន្លឹះដ៏សំខាន់សម្រាប់ជំរុញឱ្យមានកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យផ្សេងៗ ការអភិវឌ្ឍតំបន់ជនបទ និងការបង្កើនសុខដុមនីយភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ។ នៅក្នុងនីតិកាលទី៦ នៃរដ្ឋសភា **រាជរដ្ឋាភិបាលកម្ពុជា** មានមហិច្ឆតាគ្រប់គ្រង និងជំរុញការអភិវឌ្ឍវិស័យថាមពលអគ្គិសនីដើម្បី "ឈានទៅសម្រេចឱ្យបានការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយគ្រប់គ្រាន់ មានចីរភាព អាចទុកចិត្តបាន មានគុណភាព និងមានថ្លៃសមរម្យ សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ នៅគ្រប់ទីកន្លែងទូទាំងព្រះរាជាណាចក្រកម្ពុជា"។

ក្នុងនីតិកាលទី៦ នៃរដ្ឋសភា ក្នុងក្របខណ្ឌនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ចំពោះការអភិវឌ្ឍវិស័យថាមពលអគ្គិសនី រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើៈ

អាទិភាពទី១- បន្តបញ្ចុះថ្លៃអគ្គិសនីឱ្យអ្នកប្រើប្រាស់ ពង្រីកវិសាលភាពគ្របដណ្តប់នៃបណ្តាញផ្គត់ផ្គង់អគ្គិសនីរបស់ប្រព័ន្ធបណ្តាញជាតិឱ្យបានគ្រប់ទីកន្លែងទូទាំងប្រទេស បង្កើនស្ថិរភាព និងគុណភាពនៃការផ្គត់ផ្គង់អគ្គិសនី (ចតុកោណយុទ្ធសាស្ត្រទី២-មុំទី១)។

អាទិភាពទី២- បន្តពង្រីកការតបណ្តាញអគ្គិសនីដែលមានថ្លៃអគ្គិសនីទាបជូនកម្មករ និយោជិត សិស្ស និស្សិតនៅតាមផ្ទះជួល (ចតុកោណយុទ្ធសាស្ត្រទី៣-មុំទី១)។

អាទិភាពទី៣- បន្តជំរុញការអភិវឌ្ឍនៅតំបន់ជនបទឱ្យរស់រវើក ដោយបន្តវិនិយោគលើការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនីដែលមានថ្លៃសមរម្យ មានស្ថិរភាព និងមានគុណភាពឱ្យដល់តំបន់ជនបទ (ចតុកោណយុទ្ធសាស្ត្រទី៤-មុំទី១)។

អាទិភាពទី៤- បន្តលើកទឹកចិត្ត និងបង្កើនការវិនិយោគលើប្រភពថាមពលស្អាត និងថាមពលកកើតឡើងវិញ ពិសេសប្រភពថាមពលពន្លឺព្រះអាទិត្យ ទន្ទឹមនឹងការកាត់បន្ថយការផលិតថាមពលពីប្រភពមិនស្អាត ដើម្បីធានាសន្តិសុខថាមពលរយៈពេលវែង (ចតុកោណយុទ្ធសាស្ត្រទី៤-មុំទី៤)។

### ១.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនីរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា

ក្នុងគោលបំណង "ឈានទៅសម្រេចឱ្យបានការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយគ្រប់គ្រាន់ មានចីរភាព អាចទុកចិត្តបាន មានគុណភាព និងមានថ្លៃសមរម្យ សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ នៅគ្រប់ទីកន្លែងទូទាំងព្រះរាជាណាចក្រកម្ពុជា" ក្រសួងរ៉ែ និងថាមពលដែលជាស្ថាប័នទទួលបន្ទុកវិស័យថាមពលអគ្គិសនីរបស់រាជរដ្ឋាភិបាល បានដាក់ចេញនូវយុទ្ធសាស្ត្រចំនួន ៩ចំណុច ដូចខាងក្រោមៈ

ទី១ - ធ្វើបច្ចុប្បន្នកម្មផែនការមេអភិវឌ្ឍវិស័យអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើងវិញ។

ទី២ - បន្តអភិវឌ្ឍសមត្ថភាពផលិត បញ្ជូន និងចែកចាយ សំដៅធ្វើយ៉ាងណាឱ្យកម្ពុជាមានប្រភពអគ្គិសនីគ្រប់គ្រាន់ ទាន់តាមកំណើននៃសេចក្តីត្រូវការប្រើប្រាស់ ឱ្យការផ្គត់ផ្គង់ប្រភពអគ្គិសនីពីបណ្តាញជាតិអាចគ្របដណ្តប់គ្រប់ទីកន្លែងទូទាំងប្រទេស រួមទាំងតំបន់ជនបទ និងឱ្យការចែកចាយអគ្គិសនីអាចគ្របដណ្តប់គ្រប់ភូមិទូទាំងប្រទេស។ ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ លើកកម្ពស់កម្រិតជីវភាពរស់នៅ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រជាជននៅតំបន់ជនបទ នៅក្នុងនីតិកាលទី៦ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តជំរុញការអភិវឌ្ឍនៅតំបន់ជនបទឱ្យរស់រវើក ដោយបន្តវិនិយោគលើការពង្រីកភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនី ដែលមានថ្លៃសមរម្យ មានស្ថិរភាព និងមានគុណភាពឱ្យដល់តំបន់ជនបទនៅទូទាំងប្រទេស។

ទី៣ - ជំរុញការភ្ជាប់បណ្តាញផ្គត់ផ្គង់អគ្គិសនីឱ្យទីតាំងត្រូវការប្រើប្រាស់អគ្គិសនី ជាពិសេសលំនៅឋានដែលមិនទាន់មានអគ្គិសនីប្រើប្រាស់ ទាំងនៅក្នុងតំបន់ទីប្រជុំជន និងទាំងនៅតំបន់ជនបទ ដើម្បីសម្រេចគោលដៅឱ្យគ្រួសារជាង ៩០% មានអគ្គិសនីប្រើប្រាស់នៅឆ្នាំ២០២៣។

ទី៤ - កែលម្អការផ្តល់សេវាផ្គត់ផ្គង់អគ្គិសនី ក្នុងគោលដៅធ្វើយ៉ាងណាឱ្យការផ្គត់ផ្គង់មានភាពគ្រប់គ្រាន់ និងមាន ២៤ ម៉ោង មានគុណភាព សុវត្ថិភាព និងអាចទុកចិត្តបាន មានថ្លៃសមរម្យ និងមានភាពយុត្តិធម៌ក្នុងការវាស់វែង និងកត់ត្រាបរិមាណផ្គត់ផ្គង់នៅគ្រប់ទីកន្លែង ទាំងនៅតំបន់ទីប្រជុំជន និងទាំងនៅតំបន់ជនបទ។

ទី៥ - រៀបចំ និងអនុវត្តផែនការបន្ថយថ្លៃអគ្គិសនី ព្រមទាំងសិក្សារកលទ្ធភាពបន្ថយថ្លៃអគ្គិសនីបន្ថែមទៀតក្នុងគោលដៅសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងជំរុញការវិនិយោគនៅកម្ពុជា។

ទី៦ - ពង្រឹងយន្តការស្ថាប័ន ដើម្បីធ្វើយ៉ាងណាឱ្យទំនាក់ទំនង តួនាទី ភារកិច្ច ឋានានុក្រម និងឯករាជ្យភាពរវាងស្ថាប័ន និងអង្គភាពក្នុងវិស័យថាមពលអគ្គិសនី ប្រព្រឹត្តទៅដោយច្បាស់លាស់ និងមានប្រសិទ្ធភាព។

ទី៧ - ទាក់ទាញឱ្យឯកជនចូលរួមវិនិយោគជាមួយអគ្គិសនីកម្ពុជា ដើម្បីធ្វើយ៉ាងណាឱ្យមានការវិនិយោគគ្រប់គ្រាន់ ដោយបើកឱ្យឯកជនចូលរួមធ្វើអាជីវកម្មអគ្គិសនី ប៉ុន្តែរក្សាការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជាលើអាជីវកម្មក្នុងបណ្តាញជាតិដែលជាស្នូលនៃអាជីវកម្មទាំងមូល។

ទី៨ - ប្រើប្រាស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទក្នុងការធ្វើ Cross-Subsidy បន្ថយគម្លាតថ្លៃ និងក្នុងការផ្ទេរទុនទៅជួយអភិវឌ្ឍនៅតំបន់ជនបទដាច់ស្រយាល ដើម្បីធានាសមធម៌ក្នុងការទទួលបាន សេវាអគ្គិសនីរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ។

ទី៩ - កាត់បន្ថយផលប៉ះពាល់បរិស្ថានធម្មជាតិ និងសង្គមឱ្យបានជាអតិបរមា ចូលរួមប្រើប្រាស់ប្រភពថាមពលស្អាត និងចីរភាពក្នុងកម្រិតដែលមិនប៉ះពាល់ធំដុំ ចូលរួមក្នុងកិច្ចសហប្រតិបត្តិការវិស័យថាមពលអគ្គិសនីក្នុងក្របខ័ណ្ឌតំបន់ និងក្របខ័ណ្ឌអន្តរជាតិ។

# ឧបសម្ព័ន្ធ២
# ព័ត៌មានស្ដីពីមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ

## ២.១ ការបង្កើតនាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ

ម.អ.ជ. ដំបូងឡើយបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៤ ដើម្បីជំរុញការអភិវឌ្ឍអគ្គិសនីភាវូបនីយកម្មជនបទ។ ក្នុងឆ្នាំដំបូងនៃប្រតិបត្តិការការងារ ម.អ.ជ. បានប្រើប្រាស់ថវិកាដែលបានផ្តល់ដោយធនាគារពិភពលោក ក្រោមគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ និងខ្សែបញ្ជូន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា។ បន្ទាប់ពីគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ និងខ្សែបញ្ជូនបានបញ្ចប់នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ និង ពុំមានថវិកាសម្រាប់ស្ថាប័ននេះដំណើរការ។ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ ព្រះរាជក្រឹត្យថ្មីមួយទៀតលេខ នស/រកត/០៨១២/៧៣៤ ធ្វើវិសោធនកម្មមាត្រាខ្លះនៃព្រះរាជក្រឹត្យចាស់ ដោយផ្ទេរ ម.អ.ជ. ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា ដើម្បីឱ្យកម្ពុជាខ្លួនឯងអាចម្ចាស់ការបន្តប្រតិបត្តិការការងាររបស់ ម.អ.ជ. ផង និងក៏នៅតែអាចទទួលនូវអំណោយ និងជំនួយនានាពីខាងក្រៅមកជួយអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទកម្ពុជាបានផង។ តាមព្រះរាជក្រឹត្យថ្មីនេះ អគ្គិសនីកម្ពុជាបានបង្កើតនាយកដ្ឋានថ្មី[1] មួយហៅថា **"នាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ (ម.អ.ជ.)"** ។

នេះតំណាងឱ្យគំនិតផ្តួចផ្តើមដ៏សំខាន់របស់រាជរដ្ឋាភិបាលក្នុងការជំរុញ និងទាក់ទាញការវិនិយោគពីវិស័យឯកជននៅក្នុងហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីជនបទ។ គោលបំណង គឺដើម្បីពន្លឿនការអភិវឌ្ឍអគ្គិសនីនៅក្នុងតំបន់ទាំងនេះ ដោយផ្តល់លទ្ធភាពឱ្យជនក្រីក្រនៅតាមជនបទចំនួនកាន់តែច្រើនមានអគ្គិសនីប្រើប្រាស់ក្នុងគោលបំណងផ្សេងៗ រួមទាំងការបំភ្លឺ សកម្មភាពពាណិជ្ជកម្ម និងសិប្បកម្ម។ ការទទួលបាននេះត្រូវបានគេរំពឹងថា នឹងលើកកំពស់កម្រិតជីវភាពរស់នៅរបស់ជនក្រីក្រនៅតាមជនបទ និងរួមចំណែកដល់ភាពល្អក្នុងសង្គមកាន់តែទូលំទូលាយ។

## ២.២ រចនាសម្ព័ន្ធគ្រប់គ្រង

ម.អ.ជ. ប្រតិបត្តិការស្របតាមលក្ខន្តិកៈរបស់អគ្គិសនីកម្ពុជា និងមានលក្ខណៈសង្គមកិច្ច និងមានគណនីដាច់ដោយឡែក។

## ២.៣ បណ្ណាល័យ

ម.អ.ជ. ក៏មានបណ្ណាល័យសម្រាប់សាធារណជន សម្រាប់ផ្តល់ជាធនធានដើម្បីស្វែងយល់ពីសកម្មភាពរបស់ ម.អ.ជ. របាយការណ៍ និងការអភិវឌ្ឍអគ្គិសនីជនបទក្នុងព្រះរាជាណាចក្រកម្ពុជា។





[1] សេចក្តីសម្រេចលេខ ០៨៩៨សសរ.អក.រប ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការកំណត់ថ្នាក់អង្គភាពមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទក្នុងអង្គការលេខ និងរចនាសម្ព័ន្ធគ្រប់គ្រងអគ្គិសនីកម្ពុជា។

## ២.៤ ប្រភពមូលនិធិ

ប្រភពមូលនិធិដល់ ម.អ.ជ.[2] មានដូចខាងក្រោម៖

១. កញ្ចប់ថវិកាសង្គមកិច្ចដែលបានគ្រោងក្នុងបញ្ជីថ្លៃលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជា និងអំណោយដទៃទៀតរបស់អគ្គិសនីកម្ពុជា ប្រសិនបើមាន។
២. អំណោយ និងជំនួយឥតសំណងដែលប្រភពនិងលក្ខខណ្ឌនៃការផ្តល់ត្រូវបានទទួលការឯកភាពពីក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
៣. ថវិកាពីរាជរដ្ឋាភិបាលកម្ពុជា។

## ២.៥ ថវិកាជំនួយដែល ម.អ.ជ. បានទទួល និងប្រើប្រាស់

ក្នុងឆ្នាំ២០២៣ ម.អ.ជ. ទទួលបានថវិកាពីអគ្គិសនីកម្ពុជា ចំនួន ៤៧៤,២៥ប៊ីលានរៀល សម្រាប់អនុវត្តន៍កម្មវិធីរុញផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ។ ថវិកាទទួលបានពីអគ្គិសនីកម្ពុជាក៏សម្រាប់ចំណាយប្រតិបត្តិការរបស់ ម.អ.ជ. ផងដែរ។

ថវិកាទទួលបាននេះ ម.អ.ជ. បានយកទៅប្រើប្រាស់ក្នុងការអនុវត្តកម្មវិធីរុញផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ ដូចខាងក្រោម៖

១. កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ។
២. កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ។
៣. កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ។
៤. កម្មវិធីផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនី ដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនីដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយប្រព័ន្ធបណ្តាញជាតិ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទ ក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២៣ តាមបណ្តាខេត្តនិងរាជធានី។
៥. កម្មវិធីអនុវត្តអត្រាថ្លៃលក់អនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទក្នុងវិស័យកសិកម្ម ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីដែលទទួលប្រភពពីបណ្តាញជាតិ។

[2] ព្រះរាជក្រឹត្យលេខ នស/រកត/០៨១២/៧៣៤ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ ស្តីពីវិសោធនកម្មលើមាត្រា២ មាត្រា៥ និងមាត្រា៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើត ម.អ.ជ. និងលើមាត្រា៤ថ្មីនៃព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៦៤ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨ ស្តីពីវិសោធនកម្មមាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើត ម.អ.ជ.។

# ឧបសម្ព័ន្ធ៣
# ព័ត៌មានស្តីពីគោលបំណង បេសកកម្ម និងកម្មវិធីរុញផ្លែផ្កា នៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ

## ៣.១ គោលបំណង

គោលបំណងរបស់ ម.អ.ជ.[3] មានដូចខាងក្រោម៖

១. ជំរុញឱ្យមានសមធម៌ក្នុងការទទួលសេវាកម្មអគ្គិសនី ដោយជួយឱ្យប្រជាជននៅជនបទបានទទួលអគ្គិសនីប្រើប្រាស់តាមថ្លៃ ដែលអាចជាវបានសម្រាប់សេដ្ឋកិច្ច សង្គម និងលំនៅឋាន រួមចំណែកកាត់បន្ថយភាពក្រីក្រ។

២. ជំរុញ និងលើកទឹកចិត្តផ្នែកឯកជនឱ្យចូលរួមវិនិយោគធ្វើសេវាកម្មអគ្គិសនីនៅតំបន់ជនបទ ប្រកបដោយចីរភាព ជាពិសេសក្នុងការអនុវត្តបច្ចេកវិទ្យាថ្មី និងថាមពលកកើតឡើងវិញដែលមានលក្ខណៈបច្ចេកទេស និងពាណិជ្ជកម្មសមស្រប។

## ៣.២ បេសកកម្ម

ម.អ.ជ. មានបេសកកម្ម ដូចខាងក្រោម៖

១. ជំរុញវិសាលភាពអគ្គិសនីភាវូបនីយកម្មជនបទប្រកបដោយសមភាព ដោយសម្រួលឱ្យប្រជាពលរដ្ឋជនបទទទួលបានអគ្គិសនីប្រើប្រាស់ជាលក្ខណៈសេដ្ឋកិច្ច សង្គមកិច្ច និងគ្រួសារ។

២. ផ្តល់ការគាំទ្រដល់ការរៀបចំ និងអនុវត្តគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ។

៣. ផ្តល់ការគាំទ្រ និងជួយសម្រួលដល់គ្រួសារក្រីក្ររស់នៅតំបន់ជនបទអាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយការផ្តល់ជាប្រាក់កម្ចីអនុគ្រោះគ្មានការប្រាក់ ប្រាក់ឧបត្ថមធន (ប្រាក់អំណោយ) និងជាសម្ភារអគ្គិសនីជាអំណោយ។

៤. ផ្តល់ការគាំទ្រ និងជួយសម្រួលឱ្យគ្រួសារជនបទរស់នៅតំបន់ដាច់ស្រយាល ដែលខ្សែបណ្តាញអគ្គិសនីមិនទាន់អាចពង្រីកទៅដល់ក្នុងរយៈពេលយូរ អាចទទួលបានអគ្គិសនីប្រើប្រាស់តាមរយៈប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ។

៥. ផ្តល់ការគាំទ្រ និងជួយសម្រួលឱ្យអ្នកផ្គត់ផ្គង់អគ្គិសនីឯកជននៅតំបន់ជនបទដែលមានអាជ្ញាបណ្ណស្របច្បាប់ អាចមានទុនសម្រាប់ធ្វើការវិនិយោគពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីឱ្យពេញដែនអាជ្ញាបណ្ណចែកចាយរបស់ខ្លួន ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់គ្រួសារអាចភ្ជាប់ចរន្តប្រើប្រាស់តាមលទ្ធភាពរបស់ខ្លួន។

៦. ផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនី ដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយប្រព័ន្ធបណ្តាញជាតិ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទ ក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២៣ តាមបណ្តាខេត្តនិងរាជធានី។

៧. ផ្តល់ការគាំទ្រ និងជួយសម្រួលដល់អ្នកប្រើប្រាស់អគ្គិសនីគ្រប់ប្រភេទ ក្នុងវិស័យកសិកម្មទទួលបានតម្លៃអនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ ចាប់ពីម៉ោង

[3] មាត្រា៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើតស្ថាប័ន ម.អ.ជ.។

៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីដែលទទួលប្រភពពីបណ្តាញជាតិ និងនូវតម្លៃធម្មតាសម្រាប់ការប្រើប្រាស់អគ្គិសនីក្នុងវិស័យកសិកម្មពេលថ្ងៃ ចាប់ពីម៉ោង ៧:០០ព្រឹក ដល់ម៉ោង ៩:០០យប់។

៨. ជំរុញការធ្វើពាណិជ្ជកម្មបច្ចេកវិទ្យាថាមពលកកើតឡើងវិញ ដែលត្រូវបានទទួលស្គាល់ជាលក្ខណៈបច្ចេកទេស និងពាណិជ្ជកម្ម។

អាស្រ័យនឹងលក្ខខណ្ឌថវិកាដែល ម.អ.ជ. ទទួលបានពីប្រភពផ្សេងៗ ម.អ.ជ. នឹងប្រើប្រាស់ឱ្យអស់លទ្ធភាព នូវធនធានដែលខ្លួនមាន ដើម្បីសម្រេចឱ្យបាននូវបេសកកម្មខាងលើ។

## ៣.៣ កម្មវិធីរុញផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ

ក្នុងឆ្នាំ២០២៣ ម.អ.ជ. បានអនុវត្តកម្មវិធី ដូចខាងក្រោម៖

### ៣.៣.១ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ និងលក្ខណៈវិនិច្ឆ័យ

គោលបំណងនៃកម្មវិធីនេះ គឺជួយដល់គ្រួសារក្រីក្ររស់នៅតំបន់ជនបទអាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធបណ្តាញជាតិ ដោយផ្តល់សម្ភារអគ្គិសនីជាអំណោយ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។

ម.អ.ជ. ផ្តល់សម្ភារអគ្គិសនីក្នុងផ្ទះ និងខ្សែចម្លងសេវាកម្មពីប្រអប់នាឡិកាស្ទង់មកដល់ផ្ទះជាអំណោយ។ អ្នកទទួលផលត្រូវទទួលបន្ទុកទូទាត់ចំនួនទឹកប្រាក់សម្រាប់ចំណាយលើការបង់ថ្លៃភ្ជាប់ចរន្ត និងប្រាក់កក់ធា ថ្លៃប្រើប្រាស់អគ្គិសនី។

លក្ខណៈវិនិច្ឆ័យសម្រាប់ការអនុវត្តន៍កម្មវិធីនេះ មានដូចខាងក្រោម៖

#### ក. លក្ខណៈវិនិច្ឆ័យសម្រាប់អ្នកកាន់អាជ្ញាបណ្ណ

1. មានអាជ្ញាបណ្ណធ្វើសេវាកម្មអគ្គិសនីចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា។
2. អនុវត្តនៅតំបន់ជនបទ ដែលមានប្រភពផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិ។
3. យល់ព្រមដំឡើងសម្ភារអគ្គិសនីក្នុងផ្ទះ ដូចខាងក្រោម៖
   - ខ្សែចម្លងទង់ដែងស្រោម PVC មុខកាត់ 2x1.5mm$^2$ ប្រវែង ១៥ម៉ែត្រ។
   - ឌីស្យុងទ័រមេ ២ប៉ូល កម្លាំង ១០អំពែរ រួមទាំងជើងឌីស្យុងទ័រ និងប្រអប់ឌីស្យុងទ័រ ចំនួន ១កំប្លេ។
   - កុងតាក់និងឈ្នាប់ចរន្ត (ព្រី) មុខ៣ កម្លាំង ១០អំពែរ ចំនួន ៣គ្រាប់។
   - កន្ទុយអំពូលបំភ្លឺ ចំនួន ៣គ្រាប់។
   - អំពូលបំភ្លឺ LED អានុភាព ១១វ៉ាត់ ចំនួន ៣អំពូល។
4. យល់ព្រមតម្លើងខ្សែចម្លងពីចំណុចភ្ជាប់ចរន្ត (នាឡិកាស្ទង់លើបង្គោល) មកផ្ទះអ្នកទទួលផល ខ្សែអាលុយមីញ៉ូមស្រោម PVC មុខកាត់ 2x16mm$^2$ ប្រវែង ៨០ម៉ែត្រ ឬអាចវែងជាង ឬខ្លីជាងតាមតម្រូវការជាក់ស្តែង ដោយមានការយល់ព្រមគ្នារវាងអ្នកកាន់ អាជ្ញាបណ្ណ និងអ្នកទទួលផល។
5. ធានាថាសម្ភារអគ្គិសនីសម្រាប់ការតភ្ជាប់ចរន្តទាំងអស់ជាសម្ភារទទួលបានពី ម.អ.ជ.។
6. យល់ព្រមអនុវត្តកិច្ចសន្យារវាង ម.អ.ជ. និងអ្នកកាន់អាជ្ញាបណ្ណ សម្រាប់ផ្តល់សម្ភារអគ្គិសនីពី ម.អ .ជ. ជាអំណោយជូនអ្នកទទួលផល និងតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះអ្នកទទួលផល។

#### ខ. សម្រាប់អ្នកទទួលផល (គ្រួសារក្រីក្រនៅតំបន់ជនបទ)

1. គ្រួសារជនបទថ្មីដែលពុំធ្លាប់មានចរន្តអគ្គិសនីប្រើប្រាស់។
2. គ្រួសារជនបទមានបំណងតភ្ជាប់ចរន្តអគ្គិសនី ដែលរស់នៅក្នុងតំបន់មានការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិ។
3. លំនៅឋានឋិតថេរ និងមានសុវត្ថិភាពសម្រាប់ការតភ្ជាប់ចរន្តអគ្គិសនី។
4. យល់ព្រមផ្តល់បង្គោលឈើទ្រខ្សែចម្លងកម្ពស់អប្បបរមាពី ៤ ទៅ ៥ម៉ែត្រ និងគម្លាតអតិបរមាពីបង្គោលមួយទៅបង្គោលមួយទៀតពី ២០ ទៅ ៣០ម៉ែត្រ។
5. យល់ព្រមចុះហត្ថលេខា ឬផ្តិតមេដៃស្នាំលើតារាងសម្ភារអគ្គិសនីសម្រាប់តភ្ជាប់ចរន្តអគ្គិសនីប្រើប្រាស់ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្តល់សម្ភារអគ្គិសនីសម្រាប់ការតភ្ជាប់ចរន្តជាអំណោយជាមួយអ្នកផ្គត់ផ្គង់អគ្គិសនី។

### ៣.៣.២ កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ

គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលឱ្យគ្រួសារជនបទនៅតំបន់ដាច់ស្រយាល ដែលខ្សែបណ្តាញអគ្គិសនីមិនទាន់អាចពង្រីកទៅដល់ក្នុងរយៈពេលយូរ អាចទទួលបានអគ្គិសនីប្រើប្រាស់ដោយផ្តល់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះជាអំណោយជូនគ្រួសារជនបទ។

### ៣.៣.៣ កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ

គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលដល់អ្នកផ្គត់ផ្គង់អគ្គិសនីនៅជនបទដែលមានអាជ្ញាបណ្ណស្របច្បាប់អាចមានទុនសម្រាប់ធ្វើការវិនិយោគពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីឱ្យពេញដែនអាជ្ញាបណ្ណចែកចាយរបស់ខ្លួន ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់គ្រួសារអាចតភ្ជាប់ចរន្តប្រើប្រាស់តាមលទ្ធភាពរបស់ខ្លួន។

លក្ខណៈវិនិច្ឆ័យសម្រាប់ការអនុវត្តកម្មវិធីនេះចែកចេញជា ៣តំបន់ ផ្អែកលើដង់ស៊ីតេប្រជាពលរដ្ឋដូចខាងក្រោម៖

#### តំបន់១- តំបន់មានប្រជាពលរដ្ឋរស់នៅច្រើន ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ច

ម.អ.ជ. ផ្តល់ការធានាលើការខ្ចីឥណទានពីធនាគារក្នុងស្រុករបស់អ្នកកាន់អាជ្ញាបណ្ណអគ្គិសនីនៅតំបន់ជនបទ ដើម្បីយកទៅវិនិយោគលើការអភិវឌ្ឍការផ្គត់ផ្គង់អគ្គិសនីឱ្យពេញដែនអាជ្ញាបណ្ណចែកចាយរបស់ខ្លួន។

លក្ខណៈវិនិច្ឆ័យសម្រាប់តំបន់១ មានដូចខាងក្រោម៖

១. អ្នកកាន់អាជ្ញាបណ្ណត្រូវមានអាជ្ញាបណ្ណធ្វើសេវាកម្មអគ្គិសនី ដែលមានសុពលភាពចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងអាជ្ញាបណ្ណត្រូវមានអាណត្តិយ៉ាងតិច ៥ឆ្នាំ ចាប់ពីកាលបរិច្ឆេទខ្ចីប្រាក់។

២. អ្នកកាន់អាជ្ញាបណ្ណត្រូវមានការកត់ត្រា និងមានរបាយការណ៍គណនេយ្យត្រឹមត្រូវ លើការធ្វើអាជីវកម្មអគ្គិសនីកន្លងមក បញ្ជាក់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា។

៣. ឥណទានពីធនាគារ ឬហៅថាប្រាក់កម្ចីពីធនាគារនេះ គឺសម្រាប់អ្នកកាន់អាជ្ញាបណ្ណយកទៅធ្វើការវិនិយោគអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនី នៅក្នុងដែនអាជ្ញាបណ្ណរបស់ខ្លួនដែលជាតំបន់ជនបទ និងដែលភ្ជាប់ពីប្រព័ន្ធបណ្តាញជាតិប៉ុណ្ណោះ ។

៤. ដើម្បីធានារ៉ាប់រងថា អ្នកកាន់អាជ្ញាបណ្ណពិតជាសងឥណទាន និងការប្រាក់ឱ្យធនាគារ ចំពោះឥណទានដែល ម.អ.ជ. ធ្វើការធានាចំពោះធនាគារនោះ អ្នកកាន់អាជ្ញាបណ្ណត្រូវយល់ព្រមចុះហត្ថលេខា និងផ្តិតស្នាមមេដៃ លើលិខិតអនុញ្ញាតឱ្យចូលកាន់កាប់អាជីវកម្ម រួមជាមួយអចលនទ្រព្យដែលមានក្នុងអាជ្ញាបណ្ណរបស់សេវាករទាំងអស់ និងផ្ទេរអាជ្ញាបណ្ណរបស់សេវាករទៅឱ្យសេវាករថ្មីមួយទៀតទុកជាមុនឱ្យ ម.អ.ជ. ដែល ម.អ.ជ. អាចប្រើប្រាស់លិខិតនេះដើម្បីចាត់វិធានការណ៍ ក្នុងករណីដែលអ្នកកាន់អាជ្ញាបណ្ណខកខានពុំបានបង់រំលស់ឥណទាន រួមទាំងការប្រាក់ឱ្យធនាគារ។

៥. អ្នកកាន់អាជ្ញាបណ្ណ ត្រូវមានការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជាលើលក្ខខណ្ឌ ដែលខ្លួនត្រូវអនុវត្តជាមួយ ម.អ.ជ. ក្នុងកិច្ចសន្យាធានាការខ្ចីប្រាក់ពីធនាគារ រាប់ទាំងការយល់ព្រមផ្ទេរអាជ្ញាបណ្ណឱ្យអគ្គិសនីកម្ពុជា ក្នុងករណីដែលខ្លួនមិនបានសងប្រាក់តាមការកំណត់។

### តំបន់២- តំបន់មានប្រជាពលរដ្ឋរស់នៅមធ្យម ដែលការធ្វើអាជីវកម្មផ្គត់ផ្គង់អគ្គិសនីអាចពុំចំណេញ ប្រសិនបើអ្នកផ្គត់ផ្គង់អគ្គិសនីត្រូវបង់ការប្រាក់លើដើមទុនវិនិយោគ

ចំពោះតំបន់២ ដែលជាតំបន់មានដង់ស៊ីតេនៃការប្រើប្រាស់អគ្គិសនីមធ្យម ដែលការធ្វើអាជីវកម្មផ្គត់ផ្គង់អគ្គិសនីអាចពុំមានចំណេញ ប្រសិនបើអ្នកកាន់អាជ្ញាបណ្ណត្រូវបង់ការប្រាក់លើដើមទុនវិនិយោគ។ ម.អ.ជ. អាចផ្តល់ប្រាក់កម្ចីដោយពុំយកការប្រាក់ឱ្យទៅអ្នកកាន់អាជ្ញាបណ្ណ ដែលកំពុងធ្វើការផ្គត់ផ្គង់អគ្គិសនីនៅតំបន់២នេះ សម្រាប់យកទៅវិនិយោគអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅក្នុងដែនអាជ្ញាបណ្ណរបស់ខ្លួន។ មូលនិធិរបស់ ម.អ.ជ. ខាងលើនេះ មានគោលដៅចំនួន២ គឺ៖ (i)- ជួយជំរុញការពង្រីក និងការកែលម្អការផ្គត់ផ្គង់អគ្គិសនីតង់ស្យុងមធ្យម និង/ឬតង់ស្យុងទាបនៅតំបន់ជនបទ និង (ii)- ជួយលើកទឹកចិត្តដល់ការផលិតសម្ភារ និងបរិក្ខារអគ្គិសនីក្នុងស្រុក។

លក្ខណៈវិនិច្ឆ័យសម្រាប់តំបន់២ មានដូចខាងក្រោម៖

១. អ្នកកាន់អាជ្ញាបណ្ណត្រូវមានអាជ្ញាបណ្ណធ្វើសេវាកម្មអគ្គិសនី ដែលមានសុពលភាពចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងអាជ្ញាបណ្ណត្រូវមានអាណត្តិយ៉ាងតិច ៥ឆ្នាំ ចាប់ពីកាលបរិច្ឆេទខ្ចីប្រាក់។

២. អ្នកកាន់អាជ្ញាបណ្ណត្រូវមានការកត់ត្រា និងមានរបាយការណ៍គណនេយ្យត្រឹមត្រូវលើការធ្វើអាជីវកម្មអគ្គិសនីកន្លងមក បញ្ជាក់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

៣. ប្រាក់កម្ចីដោយពុំយកការប្រាក់នេះ គឺសម្រាប់យកទៅវិនិយោគលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ដែលមានប្រភពចេញពីប្រព័ន្ធបណ្តាញជាតិ។

៤. អ្នកកាន់អាជ្ញាបណ្ណត្រូវប្រើប្រាស់ប្រាក់កម្ចីដោយពុំយកការប្រាក់នេះ សម្រាប់តែវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីតង់ស្យុងមធ្យម និងតង់ស្យុងទាប ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីថ្មី និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលមានស្រាប់ នៅក្នុងដែនអាជ្ញាបណ្ណរបស់ខ្លួន។

៥. អ្នកកាន់អាជ្ញាបណ្ណត្រូវដាក់ពាក្យស្នើសុំប្រាក់កម្ចីដោយពុំយកការប្រាក់នេះពី ម.អ.ជ. ដោយមានភ្ជាប់ជាមួយនូវ (i)- ផែនការអភិវឌ្ឍន៍គម្រោងលម្អិត (ii)- បញ្ជីប៉ាន់ស្មានតម្លៃនៃគម្រោង ដោយគិតទាំងថ្លៃសម្ភារអគ្គិសនី និងទាំងថ្លៃសាងសង់សម្រាប់ការអភិវឌ្ឍគម្រោង

(iii)- ច្បាប់ចម្លងឯកសារអាជ្ញាបណ្ណ និងការកែសម្រួលពាក់ព័ន្ធទាំងអស់ (iv)- របាយការណ៍ចំណូល-ចំណាយ-បញ្ជីអចលនទ្រព្យ និងដើមទុន ដែលបានវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី (v)-លិខិតស្នើសុំការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងផ្ទេរអាជីវកម្មអគ្គិសនីដែលមានក្នុងអាជ្ញាបណ្ណឲ្យទៅអគ្គិសនីកម្ពុជា ក្នុងករណីអ្នកកាន់អាជ្ញាបណ្ណមិនបានសងប្រាក់ ដូចមានក្នុងកិច្ចសន្យារវាង ម.អ.ជ. និងអ្នកកាន់អាជ្ញាបណ្ណ និង (vi)- ឯកសារដទៃទៀតដែល ម.អ.ជ. តម្រូវឱ្យអ្នកកាន់អាជ្ញាបណ្ណផ្តល់ សម្រាប់ការពិនិត្យលើសំណើសុំប្រាក់កម្ចី។

៦. ម.អ.ជ. ពិនិត្យពាក្យស្នើសុំ និងពិនិត្យតម្លៃសរុបនៃគម្រោងដែលបានស្នើសុំ ដោយគិតតាមអត្រានៃថ្លៃហេដ្ឋារចនាសម្ព័ន្ធនីមួយៗក្នុងគម្រោង ដែលអ្នកស្នើសុំបានដាក់ស្នើ។ ក្នុងករណីដែល ម.អ.ជ. ពិនិត្យឃើញថាថ្លៃហេដ្ឋារចនាសម្ព័ន្ធណាមួយក្នុងគម្រោងស្នើ ដាក់លើសពីអត្រាដែលអាជ្ញាធរអគ្គិសនីកម្ពុជាប្រើសម្រាប់ការគណនាថ្លៃដើមក្នុងឆ្នាំ ដែលស្នើសុំ ម.អ.ជ. អាចធ្វើការកែតម្រូវ និងបន្ថយតម្លៃសរុបនៃគម្រោងវិញ។ បន្ទាប់ពីកំណត់អំពីតម្លៃសរុបនៃគម្រោងរួច ម.អ.ជ. នឹងអនុម័តអំពីចំនួនទឹកប្រាក់កម្ចីដោយពុំយកការប្រាក់ដែល ម.អ.ជ. អាចផ្តល់ឱ្យអ្នកស្នើសុំ និងចុះហត្ថលេខាលើកិច្ចសន្យាសម្រាប់ការទូទាត់ប្រាក់ និងការសងប្រាក់មកវិញ ដោយធ្វើការពិគ្រោះយោបល់ជាមួយអាជ្ញាធរអគ្គិសនីកម្ពុជា។ ចំនួនទឹកប្រាក់កម្ចីដោយពុំយកការប្រាក់នេះ គឺត្រូវមានចំនួនមិនលើសពី ៣០០.០០០(បីរយពាន់) ដុល្លារអាមេរិក ក្នុង១គម្រោង។ អ្នកកាន់អាជ្ញាបណ្ណត្រូវចេញដើមទុនវិនិយោគលើគម្រោងយ៉ាងតិច ២០% នៃថ្លៃវិនិយោគសរុបរបស់គម្រោង។ ម.អ.ជ. ត្រូវមានការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជាលើលក្ខខណ្ឌនានា ក្នុងការផ្ទេរអាជ្ញាបណ្ណរបស់អ្នកកាន់អាជ្ញាបណ្ណឱ្យទៅអគ្គិសនីកម្ពុជា ក្នុងករណីអ្នកខ្ចីមិនបានសងឥណទានតាមការកំណត់ ដែលអ្នកកាន់អាជ្ញាបណ្ណបានឯកភាព ដូចមានក្នុងកិច្ចសន្យារវាង ម.អ.ជ. និងអ្នកកាន់អាជ្ញាបណ្ណ។

៧. អ្នកកាន់អាជ្ញាបណ្ណត្រូវដាក់ពាក្យស្នើសុំមក ម.អ.ជ. ដោយមានភ្ជាប់នូវរបាយការណ៍វឌ្ឍនភាពមកជាមួយ ដើម្បីស្នើសុំទូទាត់ប្រាក់កម្ចីនេះ។ ម.អ.ជ. ផ្ទៀងផ្ទាត់វឌ្ឍនភាពការងារ និងធ្វើការផ្តល់តាមដំណាក់កាលៗ ដោយផ្អែកលើវឌ្ឍនភាពការងារ។ ម.អ.ជ. ត្រូវចេញលិខិតទទួលស្គាល់ពីចំនួនទឹកប្រាក់កម្ចីដែល ម.អ.ជ. បានទទួលមកវិញ នៅពេលអ្នកកាន់អាជ្ញាបណ្ណបានបង់រំលស់សងប្រាក់កម្ចីមក ម.អ.ជ. វិញគ្រប់ចំនួន។

៨. ចំនួនទឹកប្រាក់ឱ្យខ្ចីនេះ គឺមិនលើសពីចំនួន ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក ក្នុង១គម្រោង។ អ្នកកាន់អាជ្ញាបណ្ណអាចស្នើសុំអនុវត្តគម្រោងថ្មីទៀតបាន ពេលចាំបាច់។

៩. រយៈពេលសងប្រាក់មក ម.អ.ជ. វិញ គឺមិនលើសពី ៨ឆ្នាំ ក្នុងករណីដែលអាណត្តិអាជ្ញាបណ្ណមានរយៈពេលវែងជាង ៨ឆ្នាំ ឬមិនលើសពីអាណត្តិអាជ្ញាបណ្ណគិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យខ្ចីប្រាក់ឆ្នាំ ក្នុងករណីដែលអាណត្តិអាជ្ញាបណ្ណនៅសល់រយៈពេលតិចជា ៨ឆ្នាំ។

១០. ករណីប្រាក់កម្ចីដោយពុំយកការប្រាក់ សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីថ្មី និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលមានស្រាប់តង់ស្យុងមធ្យម ត្រូវមានការបញ្ជាក់ពីនាយកដ្ឋានផែនការយុទ្ធសាស្ត្រ និងគម្រោងការ ដើម្បីជៀសវាងការជាន់ផែនការអភិវឌ្ឍន៍របស់អគ្គិសនីកម្ពុជា។

១១. ដោយសារថវិការបស់ ម.អ.ជ. ដែលផ្តល់ជាប្រាក់កម្ចីគ្មានការប្រាក់ឱ្យអ្នកកាន់អាជ្ញាបណ្ណចេញពីមូលនិធិដែលមានគោលដៅជួយជំរុញការពង្រីក និងការកែលម្អការផ្គត់ផ្គង់អគ្គិសនី

នៅតំបន់ជនបទផង និងជួយលើកទឹកចិត្តដល់ឧស្សាហកម្មផលិតសម្ភារ និងបរិក្ខារអគ្គិសនីក្នុងស្រុកផង ដូច្នេះអ្នកស្នើសុំប្រើប្រាស់មូលនិធិនេះ ត្រូវជួយប្រើប្រាស់សម្ភារ និងបរិក្ខារអគ្គិសនីដែលមានផលិតក្នុងស្រុកឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីចូលរួមគាំទ្រឧស្សាហកម្មផលិតសម្ភារ និងបរិក្ខារអគ្គិសនីក្នុងស្រុករបស់កម្ពុជា។ ចំពោះសម្ភារ និងបរិក្ខារដែលមានលក្ខណៈសំខាន់ក្នុងការផ្គត់ផ្គង់អគ្គិសនី អ្នកស្នើសុំមានកាតព្វកិច្ចត្រូវតែប្រើសម្ភារនិងបរិក្ខារអគ្គិសនីចេញពីរោងចក្រផលិតសម្ភារ និងបរិក្ខារអគ្គិសនីកំណត់មួយចំនួន ដែលអគ្គិសនីកម្ពុជាបានចេញប្រកាសទទួលស្គាល់ និងណែនាំឱ្យសេវាករប្រើប្រាស់ លើកលែងតែក្នុងករណីដែលគុណភាពនៃសម្ភារ និងបរិក្ខារអគ្គិសនីដែលអគ្គិសនីកម្ពុជាបានប្រកាសទទួលស្គាល់ និងណែនាំឱ្យសេវាករប្រើប្រាស់នោះ ទាបជាងស្តង់ដារដែលមានជាធរមាននៅកម្ពុជា និង/ឬ ថ្លៃលក់សម្ភារ និងបរិក្ខាអគ្គិសនីដែលអគ្គិសនីកម្ពុជាបានប្រកាសទទួលស្គាល់ និងណែនាំឱ្យសេវាករប្រើប្រាស់នោះ លើសពីថ្លៃដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានកំណត់ក្នុងការគណនាថ្លៃដើមអគ្គីសនីពិតរបស់សេវាករ នៅក្នុងឆ្នាំដែលគម្រោងត្រូវអនុវត្ត។ ប្រសិនបើ អ្នកកាន់អាជ្ញាបណ្ណខកខានមិនបានប្រើប្រាស់សម្ភារ និងបរិក្ខារអគ្គិសនីចេញពីរោងចក្រផលិតសម្ភារ និងបរិក្ខារអគ្គិសនីដែលអគ្គិសនីកម្ពុជាបានប្រកាសទទួលស្គាល់ និងណែនាំឱ្យប្រើប្រាស់ខាងលើនេះទេ ម.អ.ជ. អាចមានសិទ្ធិមិនផ្តល់ចំនួនថវិកាស្មើនឹងថ្លៃនៃសម្ភារ និងបរិក្ខារដែលសេវាករត្រូវប្រើប្រាស់ខាងលើ។ ប្រសិនបើ មានការខ្វែងគំនិតរវាង ម.អ.ជ. និងអ្នកស្នើសុំអំពីគុណភាព និងថ្លៃនៃសម្ភារ និងបរិក្ខារអគ្គិសនីដែលអគ្គិសនីកម្ពុជាបានប្រកាសទទួលស្គាល់ និងណែនាំឱ្យសេវាករប្រើប្រាស់ នោះការសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាដែលជាអាជ្ញាកណ្តាល ត្រូវចាត់ទុកជាការសម្រេចចុងក្រោយ។

១២. ករណីអ្នកកាន់អាជ្ញាបណ្ណមានអាជ្ញាបណ្ណហើយ ចំនួនទឹកប្រាក់កម្ចីនេះ គឺមិនលើសពី ៧៥% នៃតម្លៃហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលមានស្រាប់របស់អ្នកកាន់អាជ្ញាបណ្ណ យោងតាមការវាយតម្លៃរបស់អាជ្ញាធរអគ្គិសនីកម្ពុជា។ ក្នុងករណីអ្នកកាន់អាជ្ញាបណ្ណថ្មី ចំនួនទឹកប្រាក់កម្ចី គឺមិនលើសពី ៧៥% នៃតម្លៃហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ដែលបានស្នើសុំរបស់អ្នកកាន់អាជ្ញាបណ្ណ យោងតាមការវាយតម្លៃរបស់អាជ្ញាធរអគ្គិសនីកម្ពុជា។

១៣. អ្នកកាន់អាជ្ញាបណ្ណត្រូវយល់ព្រមអនុវត្តកិច្ចសន្យា និងឯកសារផ្លូវច្បាប់នានាជាមួយ ម.អ.ជ.។

១៤. ប្រភពថវិកា គឺពីអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់។

### តំបន់៣- តំបន់មានប្រជាពលរដ្ឋរស់នៅតិចតួច ដែលការធ្វើអាជីវកម្មផ្គត់ផ្គង់អគ្គិសនីមិនចំណេញ លុះត្រាតែមានការផ្តល់ប្រាក់ឧបត្ថម្ភធនមួយផ្នែក លើដើមទុនវិនិយោគហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី

ចំពោះតំបន់៣ ដែលជាតំបន់មានដង់ស៊ីតេនៃការប្រើប្រាស់អគ្គិសនីតិចតួច ដែលការធ្វើអាជីវកម្មផ្គត់ផ្គង់អគ្គិសនីមិនចំណេញ លុះត្រាតែមានការផ្តល់ប្រាក់ឧបត្ថម្ភធនមួយផ្នែកលើទុនវិនិយោគហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី។ ម.អ.ជ. អាចផ្តល់ប្រាក់កម្ចីដោយពុំយកការប្រាក់ បូកជាមួយប្រាក់ឧបត្ថមធន (ប្រាក់អំណោយ) ឱ្យទៅអ្នកកាន់អាជ្ញាបណ្ណដែលកំពុងធ្វើការផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់៣ សម្រាប់យកទៅវិនិយោគអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនី ដែលមានក្នុងដែនអាជ្ញាបណ្ណរបស់អ្នកកាន់អាជ្ញាបណ្ណ។ មូលនិធិរបស់ ម.អ.ជ. ខាងលើនេះ មានគោលដៅចំនួន២

គឺៈ (i)- ជួយជំរុញការពង្រីកការផ្គត់ផ្គង់អគ្គិសនីទៅកាន់តំបន់ជនបទ និង (ii)- ជួយលើកទឹកចិត្ត ដល់ការផលិតសម្ភារ និងបរិក្ខារអគ្គិសនីក្នុងស្រុក។

លក្ខណៈវិនិច្ឆ័យសម្រាប់តំបន់៣ មានដូចខាងក្រោមៈ

១. អ្នកកាន់អាជ្ញាបណ្ណត្រូវមានអាជ្ញាបណ្ណធ្វើសេវាកម្មអគ្គិសនី ដែលមានសុពលភាពចេញ ដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងអាជ្ញាបណ្ណត្រូវមានអាណត្តិយ៉ាងតិច ៥ឆ្នាំ ចាប់ពីកាលបរិច្ឆេទខ្ចីប្រាក់។

២. អ្នកកាន់អាជ្ញាបណ្ណត្រូវមានការកត់ត្រា និងមានរបាយការណ៍គណនេយ្យត្រឹមត្រូវ លើការធ្វើអាជីវកម្មអគ្គិសនីកន្លងមក បញ្ជាក់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

៣. ប្រាក់កម្ចីដោយពុំយកការប្រាក់ បូកជាមួយប្រាក់ឧបត្ថមធន (ប្រាក់អំណោយ) នេះ គឺសម្រាប់យកទៅវិនិយោគលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនី នៅតំបន់ជនបទ ដែលមានប្រភពចេញពីប្រព័ន្ធបណ្តាញជាតិ និងបន្ទាប់ពី ម.អ.ជ. បានវាយតម្លៃជាតំបន់អាចទទួលបានប្រាក់ឧបត្ថមធន (ប្រាក់អំណោយ)។

៤. អ្នកកាន់អាជ្ញាបណ្ណត្រូវប្រើប្រាស់ប្រាក់កម្ចីដោយពុំយកការប្រាក់ បូកជាមួយប្រាក់ឧបត្ថមធន (ប្រាក់អំណោយ)នេះ សម្រាប់តែវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីតង់ស្យុងមធ្យម និងតង់ស្យុងទាប ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីថ្មី និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលមានស្រាប់ នៅក្នុងដែនអាជ្ញាបណ្ណរបស់ខ្លួន។

៥. អ្នកកាន់អាជ្ញាបណ្ណត្រូវដាក់ពាក្យស្នើសុំប្រាក់កម្ចីដោយពុំយកការប្រាក់ បូកជាមួយប្រាក់ឧបត្ថមធន (ប្រាក់អំណោយ) នេះ ពី ម.អ.ជ. ដោយមានភ្ជាប់ជាមួយនូវ (i)- ផែនការអភិវឌ្ឍន៍គម្រោងលម្អិត (ii)- បញ្ជីប៉ាន់ស្មានតម្លៃនៃគម្រោង ដោយគិតទាំងថ្លៃសម្ភារអគ្គិសនី និងទាំងថ្លៃសាងសង់សម្រាប់ការអភិវឌ្ឍគម្រោង (iii)- ច្បាប់ចម្លងឯកសារអាជ្ញាបណ្ណ និងការកែសម្រួលពាក់ព័ន្ធទាំងអស់ (iv)- របាយការណ៍ចំណូល-ចំណាយ-បញ្ជីអចលនទ្រព្យ និងដើមទុនដែលបានវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី (v)-លិខិតស្នើសុំការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងផ្ទេរអាជីវកម្មអគ្គិសនីដែលមានក្នុងអាជ្ញាបណ្ណឲ្យទៅអគ្គិសនីកម្ពុជា ក្នុងករណីអ្នកកាន់អាជ្ញាបណ្ណមិនបានសងប្រាក់ ដូចមានក្នុងកិច្ចសន្យារវាង ម.អ.ជ. និងអ្នកកាន់អាជ្ញាបណ្ណ និង(vi)- ឯកសារដទៃទៀតដែល ម.អ.ជ. តម្រូវឱ្យអ្នកកាន់អាជ្ញាបណ្ណផ្តល់សម្រាប់ការពិនិត្យលើសំណើសុំប្រាក់កម្ចី។

៦. ម.អ.ជ. ពិនិត្យពាក្យស្នើសុំ និងពិនិត្យតម្លៃសរុបនៃគម្រោងដែលបានស្នើសុំ ដោយគិតតាមអត្រានៃថ្លៃហេដ្ឋារចនាសម្ព័ន្ធនីមួយៗក្នុងគម្រោង ដែលអ្នកស្នើសុំបានដាក់ស្នើ។ ក្នុងករណីដែល ម.អ.ជ. ពិនិត្យឃើញថាថ្លៃហេដ្ឋារចនាសម្ព័ន្ធណាមួយក្នុងគម្រោងស្នើ ដាក់លើសពីអត្រាដែលអាជ្ញាធរអគ្គិសនីកម្ពុជាប្រើ សម្រាប់ការគណនាថ្លៃដើមក្នុងឆ្នាំដែលស្នើសុំ ម.អ.ជ. អាចធ្វើការកែតម្រូវ និងបន្ថយតម្លៃសរុបនៃគម្រោងវិញ។ បន្ទាប់ពីកំណត់អំពីតម្លៃសរុបនៃគម្រោងរួច ម.អ.ជ. នឹងអនុម័តអំពីចំនួនប្រាក់កម្ចីដោយពុំយកការប្រាក់ បូកជាមួយប្រាក់ឧបត្ថមធន (ប្រាក់អំណោយ) នេះ ដែល ម.អ.ជ. អាចផ្តល់សរុបឱ្យអ្នកស្នើសុំ និងចុះហត្ថលេខាលើកិច្ចសន្យាសម្រាប់ការទូទាត់ប្រាក់ និងការសងប្រាក់មកវិញ ដោយធ្វើការពិគ្រោះយោបល់ជាមួយអាជ្ញាធរអគ្គិសនីកម្ពុជា។ ចំនួនប្រាក់កម្ចីដោយពុំយកការប្រាក់ បូកជាមួយប្រាក់ឧបត្ថមធន (ប្រាក់អំណោយ)នេះ គឺត្រូវមានចំនួនមិនលើសពី

៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក ក្នុង ១គម្រោង។ អ្នកកាន់អាជ្ញាបណ្ណត្រូវចេញដើមទុនវិនិយោគលើគម្រោងយ៉ាងតិច ២០% នៃថ្លៃវិនិយោគ សរុបរបស់គម្រោង ប្រសិនបើ ៨០% នៃថ្លៃដើមវិនិយោគលើគម្រោងនេះ មានចំនួនមិនលើសពី ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។ ក្នុងករណីដែល ៨០% នៃថ្លៃដើមវិនិយោគលើគម្រោងនេះមានចំនួនលើសពី ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក ម.អ.ជ. អាចផ្តល់ប្រាក់កម្ចីដោយពុំយកការប្រាក់ បូកជាមួយប្រាក់ឧបត្ថមធន (ប្រាក់អំណោយ) នេះ ត្រឹមតែ ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក រួចអ្នកកាន់អាជ្ញាបណ្ណដែលស្នើសុំឥណទានដោយពុំយកការប្រាក់នេះ ត្រូវតែមានទុនផ្ទាល់ខ្លួន ឬទុនពីប្រភពផ្សេងទៀត ដើម្បីបង្គ្រប់ការវិនិយោគគម្រោងដែលស្នើសុំខាងលើ។ ម.អ.ជ. ត្រូវមានការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជាលើលក្ខខណ្ឌនានា ក្នុងការផ្ទេរអាជ្ញាបណ្ណរបស់អ្នកកាន់អាជ្ញាបណ្ណឱ្យទៅអគ្គិសនីកម្ពុជា ក្នុងករណីអ្នកខ្ចីមិនបានសងឥណទានដែលត្រូវសងតាមការកំណត់ ដែលអ្នកកាន់អាជ្ញាបណ្ណបានឯកភាព ដូចមានក្នុងកិច្ចសន្យារវាង ម.អ.ជ. និងអ្នកកាន់អាជ្ញាបណ្ណ។

៧. អ្នកកាន់អាជ្ញាបណ្ណត្រូវដាក់ពាក្យស្នើសុំមក ម.អ.ជ. ដោយមានភ្ជាប់នូវរបាយការណ៍វឌ្ឍនភាពមកជាមួយ ដើម្បីស្នើសុំទូទាត់ប្រាក់កម្ចីដោយពុំយកការប្រាក់ បូកជាមួយប្រាក់ឧបត្ថមធន (ប្រាក់អំណោយ) នេះ។ ម.អ.ជ. ផ្ទៀងផ្ទាត់វឌ្ឍនភាពការងារ និងធ្វើការផ្តល់តាមដំណាក់កាលៗ ដោយផ្អែកលើវឌ្ឍនភាពការងារ។ ម.អ.ជ. ត្រូវចេញលិខិតទទួលស្គាល់ពីចំនួនទឹកប្រាក់កម្ចីដែល ម.អ.ជ. បានទទួលមកវិញ នៅពេលអ្នកកាន់អាជ្ញាបណ្ណបានបង់រំលស់សងប្រាក់កម្ចីមក ម.អ.ជ. វិញគ្រប់ចំនួន។ ចំនួនទឹកប្រាក់ឧបត្ថមធន (ប្រាក់អំណោយ) ដែល ម.អ.ជ. ផ្តល់ឱ្យ គឺពុំតម្រូវឱ្យសងវិញឡើយ។

៨. ចំនួនទឹកប្រាក់ឱ្យខ្ចីនេះ គឺមិនលើសពីចំនួន ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក ក្នុង១គម្រោង។ អ្នកកាន់អាជ្ញាបណ្ណអាចស្នើសុំអនុវត្តគម្រោងថ្មីទៀតបាន ពេលចាំបាច់។

៩. រយៈពេលសងប្រាក់មក ម.អ.ជ. វិញ គឺមិនលើសពី ៨ឆ្នាំ ក្នុងករណីដែលអាណត្តិអាជ្ញាបណ្ណមានរយៈពេលវែងជាង ៨ឆ្នាំ ឬមិនលើសពីអាណត្តិអាជ្ញាបណ្ណគិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យខ្ចីប្រាក់ឆ្នាំ ក្នុងករណីដែលអាណត្តិអាជ្ញាបណ្ណនៅសល់រយៈពេលតិចជា ៨ឆ្នាំ។

១០. ករណីប្រាក់កម្ចីដោយពុំយកការប្រាក់ បូកជាមួយប្រាក់ឧបត្ថមធន (ប្រាក់អំណោយ) សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីថ្មី និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលមានស្រាប់តង់ស្យុងមធ្យម ត្រូវមានការបញ្ជាក់ពីនាយកដ្ឋានផែនការយុទ្ធសាស្ត្រ និងគម្រោងការ ដើម្បីជៀសវាងការជាន់ផែនការអភិវឌ្ឍន៍របស់អគ្គិសនីកម្ពុជា។

១១. ដោយសារថវិការបស់ ម.អ.ជ. ដែលផ្តល់ជាប្រាក់កម្ចីដោយពុំយកការប្រាក់ និងជាប្រាក់ឧបត្ថមធន (ប្រាក់អំណោយ) ឱ្យអ្នកកាន់អាជ្ញាបណ្ណខាងលើនេះ ចេញពីមូលនិធិដែលមានគោលដៅជួយជំរុញការពង្រីក និងការកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទផង និងជួយលើកទឹកចិត្តដល់ឧស្សាហកម្មផលិតសម្ភារ និងបរិក្ខារអគ្គិសនីក្នុងស្រុកផង ដូច្នេះអ្នកស្នើសុំប្រើប្រាស់មូលនិធិនេះ ត្រូវជួយប្រើប្រាស់សម្ភារ និងបរិក្ខារអគ្គិសនីដែលមានផលិតក្នុងស្រុកឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីចូលរួមគាំទ្រឧស្សាហកម្មផលិតសម្ភារ និងបរិក្ខារអគ្គិសនីក្នុងស្រុករបស់កម្ពុជា។ ចំពោះសម្ភារ និងបរិក្ខារដែលមានលក្ខណៈសំខាន់ក្នុងការផ្គត់ផ្គង់អគ្គិសនី អ្នកស្នើសុំមានកាតព្វកិច្ចត្រូវតែប្រើសម្ភារ និងបរិក្ខារអគ្គិសនីចេញពីរោងចក្រផលិតសម្ភារ និងបរិក្ខារអគ្គិសនីកំណត់មួយចំនួន ដែលអគ្គិសនីកម្ពុជា

បានចេញប្រកាសទទួលស្គាល់ និងណែនាំឱ្យសេវាករប្រើប្រាស់ លើកលែងតែក្នុងករណីដែលគុណភាពនៃសម្ភារ និងបរិក្ខារ អគ្គិសនីដែលអគ្គិសនីកម្ពុជាបានប្រកាសទទួលស្គាល់ និងណែនាំឱ្យសេវាករប្រើប្រាស់នោះ ទាបជាងស្តង់ដាដែលមានជាធរមាននៅកម្ពុជា និង/ឬថ្លៃលក់សម្ភារនិងបរិក្ខារអគ្គិសនី ដែលអគ្គិសនីកម្ពុជាបានប្រកាសទទួលស្គាល់ និងណែនាំឱ្យសេវាករប្រើប្រាស់នោះ លើសពីថ្លៃដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានកំណត់ក្នុងការគណនាថ្លៃដើមអគ្គិសនីពិតរបស់សេវាករ នៅក្នុងឆ្នាំដែលគម្រោងត្រូវអនុវត្ត។ ប្រសិនបើ អ្នកកាន់អាជ្ញាបណ្ណខកខានមិនបានប្រើប្រាស់សម្ភារ និងបរិក្ខារអគ្គិសនីចេញពីរោងចក្រផលិតសម្ភារ និងបរិក្ខារអគ្គិសនីដែលអគ្គិសនីកម្ពុជាបានប្រកាសទទួលស្គាល់ និងណែនាំឱ្យប្រើប្រាស់ខាងលើនេះទេ ម.អ.ជ. អាចមានសិទ្ធិមិនផ្តល់ចំនួនថវិកាស្មើនឹងថ្លៃនៃសម្ភារនិងបរិក្ខារ ដែលសេវាករត្រូវប្រើប្រាស់ខាងលើ។ ប្រសិនបើ មានការខ្វែងគំនិតរវាង ម.អ.ជ. និងអ្នកស្នើសុំ អំពីគុណភាព និងថ្លៃនៃសម្ភារ និងបរិក្ខារអគ្គិសនីដែលអគ្គិសនី ម្ពុជាបានប្រកាសទទួលស្គាល់ និងណែនាំឱ្យសេវាករប្រើប្រាស់ នោះការសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាដែលជាអាជ្ញាកណ្តាល ត្រូវចាត់ទុកជាការសម្រេចចុងក្រោយ។

១២. ករណីអ្នកកាន់អាជ្ញាបណ្ណមានអាជ្ញាបណ្ណហើយ ចំនួនទឹកប្រាក់កម្ចីនេះ គឺមិនលើសពី ៧៥% នៃតម្លៃហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលមានស្រាប់របស់អ្នកកាន់អាជ្ញាបណ្ណ យោងតាមការវាយតម្លៃរបស់អាជ្ញាធរអគ្គិសនីកម្ពុជា។ ក្នុងករណីអ្នកកាន់អាជ្ញាបណ្ណថ្មី ចំនួនទឹកប្រាក់កម្ចី គឺមិនលើសពី ៧៥% នៃតម្លៃហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ដែលបានស្នើសុំរបស់អ្នកកាន់អាជ្ញាបណ្ណ យោងតាមការវាយតម្លៃរបស់អាជ្ញាធរអគ្គិសនីកម្ពុជា។

១៣. អ្នកកាន់អាជ្ញាបណ្ណត្រូវយល់ព្រមអនុវត្តកិច្ចសន្យា និងឯកសារផ្លូវច្បាប់នានាជាមួយ ម.អ.ជ.។

១៤. ប្រភពថវិកា គឺពីអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់។

### ៣.៣.៤ កម្មវិធីផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនីដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយប្រព័ន្ធបណ្តាញជាតិ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២៣ តាមបណ្តាខេត្តនិងរាជធានី

គោលបំណងនៃកម្មវិធីនេះ គឺផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនីដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយប្រព័ន្ធបណ្តាញជាតិ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារជនបទ ក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២៣ តាមបណ្តាខេត្ត និងរាជធានី។

កម្មវិធីអនុវត្តន៍សម្រាប់តែការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិ ដូចនេះលក្ខណៈវិនិច្ឆ័យគឺផ្អែកតាមសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាជាបន្តបន្ទាប់[4]។

### ៣.៣.៥ កម្មវិធីអនុវត្តអត្រាថ្លៃលក់អនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទក្នុងវិស័យកសិកម្ម ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនី ដែលទទួលប្រភពពីបណ្តាញជាតិ

[4] សេចក្តីសម្រេចស្តីពីការកំណត់នីតិវិធីសម្រាប់អនុវត្តការឧបត្ថម្ភធន ដើម្បីបន្ថយថ្លៃអគ្គិសនីរវាងអាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា លេខ០១១សរ.១៦អអក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦។

គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលដល់អ្នកប្រើប្រាស់អគ្គិសនីគ្រប់ប្រភេទក្នុងវិស័យកសិកម្មទទួលបានតម្លៃអនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីដែលទទួលប្រភពពីបណ្ដាញជាតិ និងនូវតម្លៃធម្មតាសម្រាប់ការប្រើប្រាស់អគ្គិសនីក្នុងវិស័យកសិកម្មពេលថ្ងៃ ចាប់ពីម៉ោង ៧:០០ព្រឹក ដល់ម៉ោង ៩:០០យប់។

កម្មវិធីអនុវត្តន៍សម្រាប់តែអ្នកប្រើប្រាស់អគ្គិសនីគ្រប់ប្រភេទក្នុងវិស័យកសិកម្ម ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីដែលទទួលប្រភពពីបណ្ដាញជាតិ។ លក្ខណៈវិនិច្ឆ័យនេះ គឺផ្អែកតាមសេចក្ដីណែនាំរបស់អាជ្ញាធរអគ្គិសនីកម្ពុជាស្ដីពីគោលការណ៍ និងនីតិវិធីនៃការអនុវត្តអត្រាថ្លៃអនុគ្រោះពិសេស ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទក្នុងវិស័យកសិកម្មក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីដែលទទួលប្រភពពីបណ្ដាញជាតិ[5] និងគោលការណ៍របស់អគ្គិសនីកម្ពុជា/ម.អ.ជ. ស្ដីពីឯកសារមូលដ្ឋានសម្រាប់ការផ្ដល់ថ្លៃអនុគ្រោះពិសេស ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់អតិថិជនប្រភេទកសិកម្មប្រើប្រាស់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក[6]

[5] សេចក្ដីណែនាំរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលេខ ១៣០សណ២២អអក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ ស្ដីពីគោលការណ៍ និងនីតិវិធីនៃការអនុវត្តអត្រាថ្លៃអនុគ្រោះពិសេស ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទក្នុងវិស័យកសិកម្មក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីដែលទទួលប្រភពពីបណ្ដាញជាតិ។

[6] គោលការណ៍របស់អគ្គិសនីកម្ពុជា/ម.អ.ជ. លេខ ០៥៣៥/២៣មអជ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ ស្ដីពីឯកសារមូលដ្ឋានសម្រាប់ការផ្ដល់ថ្លៃអនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់អតិថិជនប្រភេទកសិកម្មប្រើប្រាស់ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក។

**ឧបសម្ព័ន្ធទី៤**

**ព័ត៌មានសង្ខេបស្តីពី ម.អ.ជ. បានចុះកិច្ចសន្យាជាមួយសេវាករតាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា សម្រាប់ផ្តល់សម្ភារអគ្គិសនីជាអំណោយជូនគ្រួសារជនបទ ដើម្បីតភ្ជាប់ចរន្តដល់ផ្ទះគ្រួសារជនបទ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ក្នុងឆ្នាំ២០២៣**

| ខេត្ត | តំបន់ធ្វើសេវាកម្ម | លេខអាជ្ញាបណ្ណ | អ្នកកាន់អាជ្ញាបណ្ណ | ប្រភពផ្គត់ផ្គង់អគ្គិសនី |
|---|---|---|---|---|
| បាត់ដំបង | ស្រុកគាស់ក្រឡ | ៤០៤អ | លោក ហេង ចន្ថារី * | អគ្គិសនីកម្ពុជា |
| | ផ្នែកខ្លះនៃស្រុកសំពៅលូន | ៥៣៣អ | ក្រុមហ៊ុន ខន & ឃន គ្រុប | អគ្គិសនីកម្ពុជា |
| កំពង់ធំ | ផ្នែកខ្លះនៃស្រុកបារាយណ៍ | ៣៦៧អ | លោក សឿន សុផល (គម្រោងទី៣) | ក្រុមហ៊ុន ប៊ីវីស៊ី ផៅវ័រ ឌីវេឡុបមេន ខូអិលធីឌី |
| | ផ្នែកខ្លះនៃស្រុកបារាយណ៍ | ៣៦៧អ | លោក សឿន សុផល (គម្រោងទី៤) | ក្រុមហ៊ុន ប៊ីវីស៊ី ផៅវ័រ ឌីវេឡុបមេន ខូអិលធីឌី |
| កណ្តាល | ផ្នែកខ្លះនៃស្រុកស្អាង | ១៧៩អ | សហគ្រាស អគ្គិសនី ញ៉ឹក ម៉ី* | ក្រុមហ៊ុន អិល អឹម ខេ |
| ក្រចេះ | ផ្នែកខ្លះនៃស្រុកសំបូរ ខេត្តក្រចេះ | ៣៤៦អ | ក្រុមហ៊ុន ជា សុខខេង ឯ.ក | អគ្គិសនីកម្ពុជា |
| ព្រះវិហារ | ផ្នែកខ្លះនៃស្រុករវៀង | ១២៨អ | សហគ្រាស អៀង ខន អេឡិកទ្រីស៊ីធី អានុភាព តំបន់ភ្នំលាក់កេរ | ក្រុមហ៊ុន ប៊ីវីស៊ី ផៅវ័រ ឌីវេឡុបមេន ខូអិលធីឌី |
| ពោធិ៍សាត់ | ផ្នែកខ្លះនៃស្រុកវាលវែង | ២៨១អ | លោក វង្ស សំបូរ | អគ្គិសនីកម្ពុជា |
| | ឃុំថ្មដា ស្រុកវាលវែង | ៣៩៦អ | លោកស្រី ប៉ៃ សុបញ្ញា | អគ្គិសនីកម្ពុជា |
| | ផ្នែកខ្លះនៃស្រុកវាលវែង | ៤០៤អ | លោក ហេង ចន្ថារី * | អគ្គិសនីកម្ពុជា |
| សៀមរាប | ផ្នែកខ្លះនៃស្រុកជីក្រែង និងស្រុកសូទ្រនិគម | ១២៩អ | សហគ្រាសអគ្គិសនី ភូមិអូរ | អគ្គិសនីកម្ពុជា |
| | ផ្នែកខ្លះនៃឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប | ៤០៦អ | លោកស្រី លឿង ស៊ីថា | អគ្គិសនីកម្ពុជា |

| | | | | |
|---|---|---|---|---|
| តាកែវ | ស្រុកបាទី និងស្រុកព្រៃកប្បាស | ១៧៩អ | សហគ្រាស អគ្គិសនី ញ៉ឹក ម៉ី * | ក្រុមហ៊ុន អិល អឹម ខេ |
| | ផ្នែកខ្លះនៃស្រុកត្រាំកក់ | ១៩៧អ | សហគ្រាសអេឡិកទ្រីស៊ីធី អង្គរកា * (គម្រោងទី២) | អគ្គិសនីកម្ពុជា |
| | ផ្នែកខ្លះនៃស្រុកកោះអណ្ដែត និងស្រុកបូរីជលសារ | ៣៧៣អ | លោក ជួន គុំ | លោក ម៉ាក់ ខុម |

**សំគាល់៖** * តំបន់ធ្វើសេវាកម្មស្ថិតក្នុងខេត្តចំនួន២ ** តំបន់ធ្វើសេវាកម្មស្ថិតក្នុងខេត្តចំនួន៣។

# ឧបសម្ព័ន្ធទី៥

ព័ត៌មានសង្ខេបស្តីពីចំនួនគ្រួសារជនបទគ្រោងតភ្ជាប់ចរន្តអគ្គិសនីជាប់កិច្ចសន្យា ចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តថ្មី និងស្ថានភាពបច្ចុប្បន្ន ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្តល់សម្ភារអគ្គិសនីជាអំណោយ ក្នុង១ខ្នងផ្ទះ ក្នុងឆ្នាំ២០២៣

| ខេត្ត | អាជ្ញាបណ្ណលេខ | អ្នកកាន់អាជ្ញាបណ្ណ | ចំនួនគ្រួសារជនបទគ្រោងតភ្ជាប់ចរន្តថ្មីជាប់កិច្ចសន្យា (គ្រួសារ) | | ចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តថ្មី (គ្រួសារ) | សំគាល់ |
|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | | |
| **I ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា** | | | | | | |
| បាត់ដំបង | ៥៣៣អ | ក្រុមហ៊ុន ខន & យន គ្រុប | - | ៧២ | ៧២ | តភ្ជាប់ចរន្តរួច |
| កំពង់ធំ | ៣៦៧អ | លោក សឿន សុផល (គម្រោងទី២) | ៤៣៥ | - | ៤៣៥ | តភ្ជាប់ចរន្តរួច |
| | | លោក សឿន សុផល (គម្រោងទី៣) | - | ៣០០ | ៣០០ | តភ្ជាប់ចរន្តរួច |
| | | លោក សឿន សុផល (គម្រោងទី៤) | - | ២៦៤ | - | កំពុងអនុវត្ត |
| ក្រចេះ | ៣៤៦អ | ក្រុមហ៊ុន ជា សុខខេង | - | ៣០០ | - | កំពុងអនុវត្ត |
| កណ្តាល | ១៧៩អ | សហគ្រាស អគ្គិសនី ញ៉ឹក ម៉ី* | - | ៨៤ | ៨៤ | តភ្ជាប់ចរន្តរួច |
| ព្រះវិហារ | ១២៨អ | សហគ្រាស អៀង ខន អេឡិកទ្រីស៊ីធី អានុភាពតំបន់ភ្នំលាក់កេរ | - | ១៥០ | - | កំពុងអនុវត្ត |
| ពោធិ៍សាត់ | ២៨១អ | លោក វង្ស សំបូរ | - | ១៧ | ១៧ | តភ្ជាប់ចរន្តរួច |
| | ៣៩៦អ | លោកស្រី ប៉ៃ សុបញ្ញា | - | ១៩ | - | កំពុងអនុវត្ត |
| | ៤០៤អ | លោក ហេង ចន្ទារី* | - | ៤៣១ | - | កំពុងអនុវត្ត |
| រតនគិរី | ៣៣៣អ | ក្រុមហ៊ុន អូរយ៉ាដាវ អេឡិកទ្រីស៊ីធី | ១២៧ | - | ១២៧ | តភ្ជាប់ចរន្តរួច |
| សៀមរាប | ១២៩អ | សហគ្រាស អគ្គិសនី ភូមិអូរ (គម្រោងទី២) | ២២០ | - | ២២០ | តភ្ជាប់ចរន្តរួច |

| | | | | | | |
|---|---|---|---|---|---|---|
| | | សហគ្រាស អគ្គិសនី ភូមិអូរ (គម្រោងទី៣) | - | ៨៧ | ៨៧ | តភ្ជាប់ចរន្តរួច |
| | ៤០៦អ | លោកស្រី លឿង ស៊ីថា | - | ២៤៣ | - | កំពុងអនុវត្ត |
| តាកែវ | ១៩៧អ | សហគ្រាសអេឡិកទ្រីស៊ីធី អង្គរកា* | ៣០០ | - | ៣០០ | តភ្ជាប់ចរន្តរួច |
| | ១៧៩អ | សហគ្រាស អគ្គិសនី ញ៉ឹក ម៉ី* | - | ១៩ | ១៩ | តភ្ជាប់ចរន្តរួច |
| | ៣៧៣អ | លោក ជួន តុំ | - | ៣៧ | ៣៧ | តភ្ជាប់ចរន្តរួច |
| | **សរុប I** | | **១.០៨២** | **២.០២៣** | **១.៦៩៨** | |
| **II ក្រោមថវិកាផ្តល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់** | | | | | | |
| កំពង់ធំ | ៣៨៧អ | សហគ្រាស អេច ធី អ ធី អេឡិកទ្រីស៊ីធី អេនធើប្រាយ | ១៥០ | - | ១៥០ | តភ្ជាប់ចរន្តរួច |
| | **សរុប II** | | **១៥០** | - | **១៥០** | |
| **សរុប I+II** | | | **១.២៣២** | **២.០២៣** | **១.៨៤៨** | |
| | | | **៣.២៥៥** | | | |

**សំគាល់៖** * តំបន់ធ្វើសេវាកម្មស្ថិតក្នុងខេត្តចំនួន២ **តំបន់ធ្វើសេវាកម្មស្ថិតក្នុងខេត្តចំនួន៣។

## ឧបសម្ព័ន្ធទី៦

### បញ្ជីឈ្មោះភូមិតាមខេត្តនីមួយៗដែលគ្របដណ្តប់តាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអេកិស៊ីឡង់អាល្លឺម៉ង់ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្តល់សម្ភារអគ្គិសនីជាអំណោយ ក្នុង១ខ្នងផ្ទះ ក្នុងឆ្នាំ២០២៣

| លរ | ខេត្ត/រាជធានី | ភូមិ | ឃុំ | ស្រុក | លេខអាជ្ញាបណ្ណ | អ្នកកាន់អាជ្ញាបណ្ណ |
|---|---|---|---|---|---|---|
| I ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា | | | | | | |
| ១ | បាត់ដំបង | ភូមិចំការល្ហុង | តាស្ដា | សំពៅលូន | ៥៣៣អ | ក្រុមហ៊ុន ខន & ឃន គ្រុប |
| | | ភូមិក្បាលហុង ភូមិប្រឡាយប្រាក់ ភូមិទឹកផុស | អង្គរបាន | | | |
| | | ភូមិអូរល្វា | ជ្រៃសីមា | | | |
| | | ភូមិឈើទាល | សិរីមានជ័យ | | | |
| | | ភូមិអូរកណ្ដាល | សន្តិភាព | | | |
| ២ | កំពង់ធំ | ភូមិត្រដែត ភូមិចើងដើង ភូមិពងទឹក ភូមិពន្លៃ ភូមិបឹង ភូមិប្រនាគ ភូមិពណ្ណរាយ | ចើងដើង | បារាយណ៍ | ៣៦៧អ | លោក សឿន សុផល (គម្រោងទី៣) |
| | | ភូមិល្បើក ភូមិតាពៅ ភូមិវាលធំ ភូមិអន្លង់វែង ភូមិអន្លង់ថ្ម ភូមិពោន | គគីរធំ | | | |
| | | ភូមិលាវ ភូមិពង្រលីង ភូមិចារ ភូមិព្រៃលោប ភូមិក្រវ៉ា ភូមិស្លាកែត ភូមិរូង | ក្រវ៉ា | | | |
| | | ភូមិសំពៅលូន ភូមិតាអោង ភូមិត្រដែត ភូមិព្រៃដុំ | ចើងដើង | | | |
| | | ភូមិត្រពាំងទូក ភូមិកំពង់ពោន ភូមិអូរចំរេះ ភូមិដោម ភូមិអណ្តោត ភូមិបាក់ស្នាក្រោម ភូមិបាក់ស្នាលើ | បាក់ស្នា | | | |
| ៣ | កំពត | ភូមិដំណាក់ឈើក្រំ | ស្នាយអញ្ជិត | ជុំគិរី | ១៩៧អ | សហគ្រាស អេឡិកទ្រីស៊ីធី អង្គរកា* (គម្រោងទី២) |
| | | ភូមិខ្ពបរុន ភូមិកំណប់ ភូមិស្រែចែង ភូមិព្រៃឃ្លៃ ភូមិពងទឹក | ស្រែចែង | | | |
| | | ភូមិត្បែងពក ភូមិព្រៃវែង ភូមិព្រៃយ៉ាវ ភូមិដំណាក់ឈ្នួល | ស្រែក្នុង | | | |
| ៤ | កណ្តាល | ភូមិរការ ភូមិគោកអណ្តែត ភូមិតាពេជ ភូមិអង្គ ភូមិចេក ភូមិសំពោង ភូមិកណ្ដាល ភូមិទួលក្រាំង ភូមិគរ ភូមិអំពិល ភូមិកំពង់ពោធិ៍ | ក្រាំងយ៉ូវ | ស្អាង | ១៧៩អ | សហគ្រាស អគ្គិសនី ញឹក ម៉ី* |
| | | ភូមិព្រៃករាំង | ទឹកវិល | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៥ | ពោធិ៍សាត់ | ភូមិស្ទឹងថ្មី | ប្រម៉ោយ | វាលវែង | ២៨១អ | លោក វង្ស សំបូរ |
| ៦ | រតនគិរី | ភូមិឡុំ ភូមិប៉ក់តូច ភូមិយ៉ាម៉ | ប៉ក់ញ៉ៃ | អូរយ៉ាដាវ | ៣៣៣អ | ក្រុមហ៊ុន អូរយ៉ាដាវ អេឡិកទ្រីស៊ីធី |
| | | ភូមិតាកុកប្រាយ ភូមិតាកុកធ្នង ភូមិព្រៃមាស ភូមិព្រិល | បរខាំ | | | |
| | | ភូមិត្រាង ភូមិប៉ាអរ ភូមិអ៊ុន | លំជ័រ | | | |
| | | ភូមិគងយុ ភូមិប្លង់ | ប៉ាតេ | | | |
| | | ភូមិប៉ាដល | សេសាន | | | |
| | | ភូមិតែនសុះ ភូមិសំ | យ៉ាទុង | | | |
| ៧ | សៀមរាប | ភូមិបឹង ភូមិទទឹងថ្ងៃ ភូមិឬស្សីលក ភូមិសំរោងកញ្ចោច ភូមិស្ពានតូច ភូមិក្រូច ភូមិយាង | ឬស្សីលក | ស្រុកជីក្រែង | ១២៩អ | សហគ្រាស អគ្គិសនី ភូមិអូរ (គម្រោងទី២) |
| | | ភូមិគីឡូតាឈឹម ភូមិបាក់អង្រុត | គោកធ្លកក្រោម | | | |
| | | ភូមិកន្សែង ភូមិដំរីឆ្លង ភូមិព្រៃប្រស់ ភូមិថ្នល់ដាច់ | សង្វើយ | | | |
| | | ភូមិឬស្សីលក ភូមិស្ពានតូច ភូមិទទឹងថ្ងៃ ភូមិបឹង ភូមិត្រពាំងរុន ភូមិសំរោងកញ្ចោច | ឬស្សីលក | ស្រុកជីក្រែង | ១២៩អ | សហគ្រាស អគ្គិសនី ភូមិអូរ (គម្រោងទី៣) |
| | | ភូមិកន្សែង ភូមិចក ភូមិដំរីឆ្លង ភូមិតាព្រុំ ភូមិថ្នល់ដាច់ ភូមិពាក់ស្ពាន ភូមិព្រៃប្រស់ ភូមិអូរ | សង្វើយ | | | |
| | | ភូមិគីឡូតាឈឹម ភូមិទទឹងថ្ងៃ ភូមិបាក់អង្រុត ភូមិបុស្សគរ | គោកធ្លកក្រោម | | | |
| ៨ | តាកែវ | ភូមិតានន ភូមិកណ្តាល ភូមិយុថ្កា ភូមិក្រាំងប្រទាល ភូមិចេក ភូមិស្វាយខម | ដូង | បាទី | ១៧៩អ | សហគ្រាស អគ្គិសនី ញ៉ឹក ម៉ី* |
| | | ភូមិត្រពាំងតាសុខ ភូមិត្រពាំងព្រីង ភូមិអង្គតាង៉ិល ភូមិព្រៃតាខាប ភូមិក្រាំងតាចាន់ ភូមិតាលាក់ខាងត្បូង ភូមិត្រពាំងលាន ភូមិត្រពាំងខន | គុស | ត្រាំកក់ | ១៩៧អ | សហគ្រាស អេឡិកទ្រីស៊ីធី អង្គរកា* (គម្រោងទី២) |
| | | ភូមិឬស្សីមួយគុម្ព ភូមិត្រពាំងភ្លូ ភូមិស្ទឹង ភូមិត្រពាំងដងទឹក ភូមិត្រពាំងខ្ទៅ ភូមិត្រពាំងក្រសាំង ភូមិត្រពាំងក្រឡាញ់ ភូមិត្នោតជុំ ភូមិសុក្រំ ភូមិបឹងសាទង | អូសារ៉ាយ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | | ភូមិព្រៃក្តួច ភូមិបុស្សតាផង់ ភូមិព្រៃតាឡយ ភូមិត្រពាំងរបង ភូមិត្រពាំងក្រញូង | ត្រពាំងក្រញូង | | | |
| | | ភូមិស្រែខ្វាវ | ដាងទង | | | |
| | | ភូមិតាគេម ភូមិម្រុំ ភូមិលីញ្ញា ភូមិត្រពាំងស្វាយ ភូមិតាកឹម | តាគេម | | | |
| | | ភូមិពាក់បង្អោង ភូមិអង្គត្រាវ ភូមិពោធិ៍ដុះ | ត្រពាំងធំខាងជើង | | | |
| | | ភូមិសំរោង ភូមិត្រពាំងជ្រៃ ភូមិគោចិនលែង ភូមិព្រៃក្តី ភូមិព្រៃព្រាល ភូមិត្រពាំងប្រីយ៍ ភូមិប្រកៀប ភូមិត្រពាំងខន ភូមិត្រពាំងកោះ ភូមិព្រៃរំដួល ភូមិត្រពាំងឈូក ភូមិត្រពាំងតាសោម ភូមិត្រពាំងត្នោត | ត្រពាំងធំខាងត្បូង | | | |
| | | ភូមិកល់គម | ត្រាំកក់ | | | |
| | | ភូមិព្រៃគគី ភូមិព្រៃតាដុក ភូមិតាសោម ភូមិសំបួរ ភូមិតាស្មន់ ភូមិចានទាប ភូមិក្របីព្រៃ ភូមិត្រពាំងថ្ម ភូមិក្រាំងបន្ទាយ ភូមិត្រពាំងចែង ភូមិពងទឹក ភូមិប្រសូត្រថ្មី | សំរោង | | | |
| | | ភូមិពងអណ្តើក ភូមិតាញឹម ភូមិតាភិន ភូមិតាហៀង ភូមិតាផាន់ | ព្រៃយុថ្កា | កោះអណ្តែត | ៣៧៣អ | លោក ជួន គុំ |
| | | ភូមិតារាគមន៍ ភូមិជ័យជោគ ភូមិអញ្ចាញ | ជ័យជោគ | បូរីជលសារ | | |
| សរុប I | | ១៦៨ ភូមិ | ៣៧ ឃុំ | ១១ ស្រុក | | |
| **II ក្រោមថវិកាផ្តល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់** | | | | | | |
| ១ | កំពង់ធំ | ភូមិស្វូដៃ ភូមិអន្លង់ក្រសាំង ភូមិត្នោត ភូមិច្រាំងក្រហម ភូមិតាអាំ | កំពង់ស្វាយ | កំពង់ស្វាយ | ៣៨៧អ | សហគ្រាស អេច.ធី.អ.ធី អេឡិកទ្រីស៊ីធី អេនធើប្រាយ |
| | | ភូមិបិណ្ឌី ភូមិអន្លង់លោក ភូមិស្វាយឃ្លោក ភូមិព្រេន ភូមិសំបួរ ភូមិព្រៃគុយ | ព្រៃគុយ | | | |
| | | ភូមិព្រៃទប់ ភូមិត្រពាំងអារ័ក្ស ភូមិល្វា | ជ័យ | | | |
| | | ភូមិល្វៃ ភូមិត្រពាំងថ្ម | ត្រពាំងឬស្សី | | | |
| | | ភូមិអាត់ស្វ៊ | សំបូរណ៍ | ប្រាសាទសំបូរ | | |

| | | | | | | |
|---|---|---|---|---|---|---|
| | | ភូមិជ័យ ភូមិខ្នាក់ ភូមិត្រពាំងផ្អៀក ភូមិចំណារ ភូមិត្រពាំងក្រោល ភូមិវាលល្អាក់ | សាលាវិស័យ | ប្រាសាទបល្ល័ង្គ | | |
| សរុប II | | ២៣ ភូមិ | ៦ ឃុំ | ៣ ស្រុក | | |
| សរុប I+II | | ១៩១ ភូមិ | ៤៣ ឃុំ | ១៤ ស្រុក | | |

**សំគាល់៖** * តំបន់ធ្វើសេវាកម្មស្ថិតក្នុងខេត្តចំនួន២ ** តំបន់ធ្វើសេវាកម្មស្ថិតក្នុងខេត្តចំនួន៣។

# ឧបសម្ព័ន្ធទី៧

## ផែនទីបង្ហាញពីខេត្តដែលបានអនុវត្តកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្តល់សម្ភារអគ្គិសនីជាអំណោយ ក្នុង១ខ្នងផ្ទះ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្នុងឆ្នាំ២០២៣



# ឧបសម្ព័ន្ធទី៨

## បញ្ជីឈ្មោះភូមិដែល ម.អ.ជ. បានដំឡើងប្រព័ន្ធសូឡា ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា ក្នុងឆ្នាំ២០២៣

| លរ. | ខេត្ត | ចំនួនភូមិបានទទួលអគ្គិសនីប្រើប្រាស់តាមរយៈប្រព័ន្ធសូឡា | ឃុំ | ស្រុក |
|---|---|---|---|---|
| **I ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា** | | | | |
| ១ | បាត់ដំបង | ភូមិព្រែកទាល់ | កោះជីវាំង | ឯកភ្នំ |
| | | ភូមិអញ្ចាញ | សង្កាត់អូរចារ | ក្រុងបាត់ដំបង |
| ២ | ពោធិ៍សាត់ | ភូមិឈើទាល | ត្នោតជុំ | ក្រគរ |
| | | ភូមិប៉ប៉ិត | អន្លង់ត្នោត | |
| | | ភូមិកំពង់លើ ភូមិសំរោង ភូមិឈើទាលខ្ពស់ ភូមិដូង ភូមិផ្សារ ភូមិទទឹង ភូមិត្រពាំងវែង | ក្បាលត្រាច | |
| | | ភូមិកំពង់ឡ ភូមិចេកចៅ ភូមិពោធិ៍របង | កំពង់ពោធិ៍ | |
| | | ភូមិទី១ ភូមិទី២ ភូមិទី៣ ភូមិទី៤ | កំពង់លួង | |
| | | ភូមិកំពង់ប្រាក់ | ស្នាអន្សា | |
| | | ភូមិកំពង់ថ្កោល | អន្សាចំបក់ | |
| | | ភូមិអូរអោកល់ ភូមិក្រាំងធំ ភូមិពុទ្រាម ភូមិអូរអោចម៍កុក | អូរសណ្តាន់ | |
| | | ភូមិរាំងទិល ភូមិព្រែក ភូមិចារុះ ភូមិកោះក្អែក | រាំងទិល | |
| ៣ | ព្រះសីហនុ | ភូមិ៣ | សង្កាត់លេខ១ | ក្រុងព្រះសីហនុ |
| ៤ | ឧត្តរមានជ័យ | ភូមិតាមាន់សែនជ័យ | គោកមន | បន្ទាយអំពិល |
| **សរុប I** | **៤ខេត្ត** | **៣០ភូមិ** | **១៣ឃុំ** | **៥ស្រុក** |
| **II ក្រោមថវិកាផ្តល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់** | | | | |
| ១ | ពោធិ៍សាត់ | ភូមិម៉ុងរឺ | ប្រម៉ោយ | វាលវែង |
| | | ភូមិបឹងរំលេច ភូមិអូរធំ | ក្រពើពីរ | |
| **សរុប II** | **១ខេត្ត** | **៣ភូមិ** | **២ឃុំ** | **១ស្រុក** |
| **សរុប I+II** | **៤ខេត្ត** | **៣៣ភូមិ** | **១៥ឃុំ** | **៦ស្រុក** |

# ឧបសម្ព័ន្ធទី៩

## ផែនទីបង្ហាញពីខេត្តបានដំឡើងប្រព័ន្ធសូឡា ក្នុងឆ្នាំ២០២៣



**ឧបសម្ព័ន្ធទី១០**

**ព័ត៌មានសង្ខេបស្តីពីការចុះកិច្ចសន្យាតាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអេកិវឡង់អាល្លឺម៉ង់**
**ក្រោមកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២៣**

| ខេត្ត | តំបន់ធ្វើសេវាកម្ម | លេខអាជ្ញាបណ្ណ | អ្នកកាន់អាជ្ញាបណ្ណ | ប្រភពផ្គត់ផ្គង់អគ្គិសនី |
|---|---|---|---|---|
| **ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា** | | | | |
| បន្ទាយមានជ័យ | ស្រុកព្រះនេត្រព្រះ ស្រុកភ្នំស្រុក | ១៦៤អ | ក្រុមហ៊ុន វឌ្ឍនៈ អិនជីអង្គរ** (គម្រោងទី៤) | អគ្គិសនីកម្ពុជា |
| | ផ្នែកខ្លះនៃស្រុកមង្គលបូរី ស្រុកព្រះនេត្រព្រះ | ៥០៤អ | លោក សុក វិច័យ * | អគ្គិសនីកម្ពុជា |
| បាត់ដំបង | ស្រុកឯកភ្នំ | ១៦៤អ | ក្រុមហ៊ុន វឌ្ឍនៈអិនជីអង្គរ** (គម្រោងទី៤) | អគ្គិសនីកម្ពុជា |
| | នៅផ្នែកខ្លះនៃស្រុកគាស់ក្រឡ | ៤០៤អ | លោក ហេង ចន្ធារី * (គម្រោងទី៤) | អគ្គិសនីកម្ពុជា |
| | ស្រុកថ្មគោល | ៥០៤អ | លោក សុក វិច័យ * | អគ្គិសនីកម្ពុជា |
| កំពង់ចាម | នៅផ្នែកខ្លះនៃស្រុកស្ទឹងត្រង់ | ៣៥៦អ | លោកស្រី អេង កល្យាន (គម្រោងទី៣) | អគ្គិសនីកម្ពុជា |
| កំពង់ស្ពឺ | ផ្នែកខ្លះនៃស្រុកភ្នំស្រួច | ២២៤អ | ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី (គម្រោងទី៦) | អគ្គិសនីកម្ពុជា |
| | ផ្នែកខ្លះនៃស្រុកបសេដ្ឋ និងស្រុកគងពិសី | ៣៨៦អ | ក្រុមហ៊ុន បសេដ្ឋ អេឡិកទ្រីស៊ីធី (គម្រោងទី៦) | អគ្គិសនីកម្ពុជា |
| | ផ្នែកខ្លះនៃស្រុកឱរ៉ាល់ | ៤៣៥អ | លោកស្រី កែវ សេងា **(គម្រោងទី៣) | អគ្គិសនីកម្ពុជា |
| កំពង់ធំ | ស្រុកស្ទោង | ១១១អ | សហគ្រាស អគ្គិសនី គង់ វុន *(គម្រោងទី៧) | អគ្គិសនីកម្ពុជា |
| កំពត | ស្រុកជុំគិរី | ១៩៧អ | សហគ្រាសអឡិកទ្រីស៊ីធី អង្គរកា*(គម្រោងទី៨) | អគ្គិសនីកម្ពុជា |
| កោះកុង | ឃុំដងពែក ស្រុកស្រែអំបិល | ៤៣៥អ | លោកស្រី កែវ សេងា**(គម្រោងទី៣) | អគ្គិសនីកម្ពុជា |
| ក្រចេះ | ផ្នែកខ្លះនៃឃុំ២ធ្នូ និងឃុំឃ្សឹម ស្រុកស្នួល | ៣៥២អ | ក្រុមហ៊ុន អេឡិចទ្រីស៊ីធីខេ៣(គម្រោងទី២) | អគ្គិសនីកម្ពុជា |
| ព្រះវិហារ | ផ្នែកខ្លះនៃស្រុករវៀង | ១២៨អ | សហគ្រាស អៀង ខន អេឡិកទ្រីស៊ីធី អានុភាព តំបន់ភ្នំលាក់កេរ (គម្រោងទី៣) | ក្រុមហ៊ុន ប៊ីវីស៊ី ផៅវ័រ ឌីវេឡុបមេន ខូអិលធីឌី |
| | ផ្នែកខ្លះនៃស្រុកជាំក្សាន្ត | ១៦២អ | ក្រុមហ៊ុន ឡេង អ៊ាង អេឡិចទ្រីស៊ីធី (គម្រោងទី៤) | ក្រុមហ៊ុន ប៊ីវីស៊ី ផៅវ័រ ឌីវេឡុបមេន ខូអិលធីឌី |
| ពោធិ៍សាត់ | ឃុំថ្មដា ស្រុកវាលវែង | ៣៩៦អ | លោកស្រី ប៉ៃ សុបញ្ញា (គម្រោងទី៣) | អគ្គិសនីកម្ពុជា |

| | | | | |
|---|---|---|---|---|
| | ផ្នែកខ្លះនៃស្រុកវាលវែង | ៤០៤អ | លោក ហេង ចន្ថារី *(គម្រោងទី៤) | អគ្គិសនីកម្ពុជា |
| | ផ្នែកខ្លះនៃស្រុកក្រគរ និងឃុំកញ្ជរ ស្រុកកណ្ដៀង | ៥០១អ | ក្រុមហ៊ុន អគ្គិសនី បឹងកន្ទួត | អគ្គិសនីកម្ពុជា |
| រតនគិរី | ផ្នែកខ្លះនៃស្រុកអណ្ដូងមាស | ៣៧២អ | លោក ស៊ាវ ពិសិដ្ឋ (គម្រោងទី៣) | អគ្គិសនីកម្ពុជា |
| សៀមរាប | ផ្នែកខ្លះនៃស្រុកជីក្រែង | ១១១អ | សហគ្រាស អគ្គិសនី គង់ វុន *(គម្រោងទី៧) | អគ្គិសនីកម្ពុជា |
| | ផ្នែកខ្លះនៃស្រុកពួក ស្រុកក្រឡាញ់ | ១៦៤អ | ក្រុមហ៊ុន វឌ្ឍនៈ អិនជីអង្គរ **(គម្រោងទី៤) | អគ្គិសនីកម្ពុជា |
| ព្រះសីហនុ | ឃុំអូរបាក់រទេះ ស្រុកកំពង់សីលា | ៤៣៥អ | លោកស្រី កែវ សេដា **(គម្រោងទី៣) | អគ្គិសនីកម្ពុជា |
| ស្វាយរៀង | ផ្នែកខ្លះនៃស្រុករមាសហែក | ៣១៩អ | ក្រុមហ៊ុនខ្មែរឃ្យូជីឡឹជីត្រេឌីង (ខេមកេនី) (គម្រោងទី៧) | អគ្គិសនីកម្ពុជា |
| តាកែវ | ផ្នែកខ្លះនៃស្រុកត្រាំកក់ | ១៩៧អ | ក្រុមហ៊ុន អេឡិកទ្រីស៊ីធី ត្រាំកក់*(គម្រោងទី៨) | អគ្គិសនីកម្ពុជា |
| **ក្រោមថវិកាផ្ដល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់** | | | | |
| បន្ទាយមានជ័យ | ឃុំណាំតៅ ស្រុកភ្នំស្រុក | ៤០១អ | លោក តាន់ លាងស្រេង (គម្រោងទី៤) | អគ្គិសនីកម្ពុជា |
| បាត់ដំបង | ផ្នែកខ្លះនៃឃុំភ្នំសំពៅ ស្រុកបាណន់ ស្រុកថ្មគោល និងក្រុងបាត់ដំបង | ២០២អ | សហគ្រាស អគ្គិសនី គង់ សាម៉ុន (គម្រោងទី៥) | អគ្គិសនីកម្ពុជា |
| កំពង់ចាម | ផ្នែកខ្លះនៃឃុំបាធាយ ស្រុកបាធាយ | ៤០០អ | លោក ហុង សេងគ្រី *(គម្រោងទី៨) | ក្រុមហ៊ុន OSVR Trading |
| កំពង់ឆ្នាំង | ផ្នែកខ្លះនៃស្រុកកំពង់ត្រឡាច | ៤០០អ | លោក ហុង សេងគ្រី *(គម្រោងទី៨) | ក្រុមហ៊ុន OSVR Trading |
| | ឃុំពាមឆ្កោក ឃុំកំពង់អុស ស្រុកជលគិរី និងផ្នែកខ្លះនៃឃុំកំពង់ហៅ ស្រុកកំពង់លែង ឃុំគោកបន្ទាយ ស្រុករលាប្អៀរ | ៤២៤អ | លោក សួន សុផានិត (គម្រោងទី៣) | ក្រុមហ៊ុន OSVR Trading |
| កំពង់ធំ | នៅផ្នែកខ្លះនៃឃុំទំរីង និងឃុំសុចិត្រ ស្រុកសណ្ដាន់ | ៣២៨អ | លោក សៀង ទី (គម្រោងទី២) | អគ្គិសនីកម្ពុជា |
| | ផ្នែកខ្លះនៃស្រុកកំពង់ស្វាយ ស្រុកប្រាសាទបល្ល័ង្ក ស្រុកប្រាសាទសំបូរ និងក្រុងស្ទឹងសែន | ៣៨៧អ | សហគ្រាស អេចជីអជី អេឡិកទ្រីស៊ីធី អេនជើប្រាយ (គម្រោងទី៤) | ក្រុមហ៊ុន ប៊ីវីស៊ីផៅវ័រ ឌីវេឡុបមេន ខូអិលធីឌី |
| កណ្ដាល | ស្រុកល្វាឯម ខេត្តកណ្ដាល | ៣៥៥អ | សហគ្រាស ឈរ វ៉េងងួន អេឡិកទ្រីស៊ីធី អេនជើប្រាយ* (គម្រោងទី៨) | អគ្គិសនីកម្ពុជា |
| ព្រះវិហារ | ផ្នែកខ្លះនៃគូលែន | ៣៣៤អ | ក្រុមហ៊ុន អគ្គិសនី អេស ឌី គូលែន (គម្រោងទី៤) | ក្រុមហ៊ុន ប៊ីវីស៊ី ផៅវ័រ |

| | | | | |
|---|---|---|---|---|
| | | | | ឌីវេឡុបមេន ខូអិលធីឌី |
| | នៅផ្នែកខ្លះនៃស្រុកធែប ស្រុកជ័យសែន និងស្រុករវៀង | ៤០៩អ | លោក អេង សុធាវឌ្ឍនា(គម្រោងទី៣) | អគ្គិសនីកម្ពុជា |
| ព្រៃវែង | នៅផ្នែកខ្លះនៃស្រុកកំពង់ត្របែក | ០៣៦អ | លោកស្រី ពេជ គីម (គម្រោងទី៤) | អគ្គិសនីកម្ពុជា |
| | ផ្នែកខ្លះនៃស្រុកពោធិ៍រៀង និងស្រុកពារាំង | ៣៥៥អ | សហគ្រាស ឈរ វែងងួន អេឡិកទ្រីស៊ីធី អេនជើប្រាយ* (គម្រោងទី៨) | អគ្គិសនីកម្ពុជា |
| ពោធិ៍សាត់ | នៅផ្នែកខ្លះនៃឃុំប្រម៉ោយ និងឃុំអន្លង់រាប ស្រុកវាលវែង | ២៨១អ | លោក វង្ស សំបូរ (គម្រោងទី៦) | អគ្គិសនីកម្ពុជា |
| | ឃុំតាលោ ស្រុកតាលោសែនជ័យ ផ្នែកខ្លះនៃឃុំខ្នារទទឹង ស្រុកបាកាន និងឃុំសំរោង ស្រុកភ្នំក្រវាញ | ៣៣២អ | ក្រុមហ៊ុន តាលោ អេឡិកទ្រីស៊ីធី (គម្រោងទី៤) | អគ្គិសនីកម្ពុជា |
| | នៅផ្នែកខ្លះនៃស្រុកកណ្តៀង ស្រុកបាកាន និងក្រុងពោធិ៍សាត់ | ៣៨៣អ | លោកស្រី គឹម ស៊ីផល (គម្រោងទី៦) | អគ្គិសនីកម្ពុជា |
| | នៅផ្នែកខ្លះនៃឃុំអូរសោម ស្រុកវាលវែង | ៣៩៧អ | លោក ប៉ាវ វុទ្ធា (គម្រោងទី៦) | អគ្គិសនីកម្ពុជា |
| សៀមរាប | ផ្នែកខ្លះនៃឃុំកន្ទួត ស្រុកស្វាយលើ ស្រុកបន្ទាយស្រី ស្រុកវ៉ារិន | ២៤០អ | ក្រុមហ៊ុន ហ៊ាង គឹមហេង អេចអេស ផៅវ័រ* (គម្រោងទី១០) | អគ្គិសនីកម្ពុជា |
| ឧត្តរមានជ័យ | ផ្នែកខ្លះនៃឃុំចុងកាល់ ស្រុកចុងកាល់ ស្រុកអន្លង់វែង | ២៤០អ | ក្រុមហ៊ុន ហ៊ាង គឹមហេង អេចអេស ផៅវ័រ* (គម្រោងទី១០) | អគ្គិសនីកម្ពុជា |
| ស្វាយរៀង | ផ្នែកខ្លះនៃស្រុករមាសហែក | ៣១៩អ | ក្រុមហ៊ុនខ្មែរយូធីឡឺធីត្រេឌីង (ខេយូធី) ខមភេនី (គម្រោងទី៨) | អគ្គិសនីកម្ពុជា |

**សំគាល់៖** * តំបន់ធ្វើសេវាកម្មស្ថិតក្នុងខេត្តចំនួន២ និង ** តំបន់ធ្វើសេវាកម្មស្ថិតក្នុងខេត្តចំនួន៣។

## ឧបសម្ព័ន្ធទី១១

### ព័ត៌មានសង្ខេបស្ដីពីប្រវែងខ្សែបណ្ដាញគ្រោងសាងសង់ជាប់កិច្ចសន្យា ប្រវែងខ្សែបណ្ដាញបានសាងសង់រួច និងស្ថានភាពបច្ចុប្បន្នតាមខេត្តនីមួយៗ ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២៣

| ខេត្ត | អាជ្ញាបណ្ណលេខ | ឈ្មោះអ្នកកាន់អាជ្ញាបណ្ណ | ប្រវែងខ្សែបណ្ដាញជាប់កិច្ចសន្យា (km) | | ប្រវែងខ្សែបណ្ដាញបានសាងសង់រួច (km) | | សំគាល់ |
|---|---|---|---|---|---|---|---|
| | | | LV | MV | LV | MV | |
| **I ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា** | | | | | | | |
| បន្ទាយមានជ័យ | ៥០៤អ | លោក សុក រិធ័យ * | ១៣,៣០ | ២៦,៧០ | ១៣,៣០ | ២៦,៧០ | បានទទួលថវិកាជួយទុន |
| កំពង់ចាម | ៣៥៦អ | លោកស្រី អេង កល្យាន (គម្រោងទី៣) | ១,៩០ | ២,១០ | - | - | កំពុងសាងសង់ |
| កំពង់ស្ពឺ | ២២៤អ | ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី (គម្រោងទី៦) | - | ១៧,៧០ | - | ១៧,៧០ | បានទទួលថវិកាជួយទុន |
| | ៣៨៦អ | ក្រុមហ៊ុន បសេដ្ឋ អេឡិកទ្រីស៊ីធី (គម្រោងទី៦) | - | ៩,២០ | - | ៩,២០ | បានទទួលថវិកាជួយទុន |
| | ៤៣៥អ | លោកស្រី កែវ សេដា (គម្រោងទី៣) | ៤,០០ | ៦,០០ | ៤,០០ | ៦,០០ | បានទទួលថវិកាជួយទុន |
| ក្រចេះ | ៣៥២អ | ក្រុមហ៊ុន អេឡិចទ្រីស៊ីធីខេ៣ (គម្រោងទី២) | ២៣,៥៣ | ១១,១៥ | ២៣,៥៣ | ១១,១៥ | បានទទួលថវិកាជួយទុន |
| ព្រះវិហារ | ១២៨អ | សហគ្រាស អៀង ខន អេឡិកទ្រីស៊ីធី អានុភាព តំបន់ភ្នំលាក់កេរ (គម្រោងទី៣) | ៨,៧០ | ៧.៦០ | ៨,៧០ | ៧.៦០ | បានទទួលថវិកាជួយទុន |
| | ១៦២អ | ក្រុមហ៊ុន ឡេង អ៊ែង អេឡិចទ្រីស៊ីធី (គម្រោងទី៤) | ៣,៨០ | ៣,០០ | ៣,៨០ | ៣,០០ | បានទទួលថវិកាជួយទុន |
| ពោធិ៍សាត់ | ៣៨២អ | លោកស្រី គឹម ស៊ីផល (គម្រោងទី៥) | - | - | ២២,០០ | - | បានទទួលថវិកាជួយទុន |
| | ៣៩៦អ | លោកស្រី ប៉ៃ សុបញ្ញា (គម្រោងទី៣) | ៥,៦០ | ៦,២០ | - | - | កំពុងសាងសង់ |
| | ៤០៤អ | លោក ហេង ចន្ទារី* (គម្រោងទី៤) | ១៩,០០ | ១១,១០ | - | - | កំពុងសាងសង់ |
| | ៥០១អ | ក្រុមហ៊ុនអគ្គិសនី បឹងកន្ទួត | ៣១,២០ | ៩,៤០ | ៣១,២០ | ៩,៤០ | បានទទួលថវិកាជួយទុន |
| រតនគិរី | ៣៧២អ | លោក ស៊ាវ ពិសិដ្ឋ (គម្រោងទី៣) | ៣,៦០ | ១៦,១៤ | ៣,៦០ | ១៦,១៤ | បានទទួលថវិកាជួយទុន |
| សៀមរាប | ១១១អ | សហគ្រាស អគ្គិសនី គង់ វុន *(គម្រោងទី៧) | ២៨,៥០ | ១៩,១០ | ២៨,៥០ | ១៩,១០ | បានទទួលថវិកាជួយទុន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ១៦៤អ | ក្រុមហ៊ុន វឌ្ឍនៈ អិន អង្គរ.ធី.**(គម្រោងទី៤) | ៨,០០ | ២២,០០ | ៨,០០ | ២២,០០ | បានទទួលថវិកាជួយទុនមួយចំនួន និងកំពុងបន្តសាងសង់ |
| តាកែវ | ១៩៧អ | សហគ្រាស អេឡិកទ្រីស៊ីធី អង្គរកា(គម្រោងទី៨) * | ២១,២៥ | ១៦,៤០ | ២១,២៥ | ១៦,៤០ | បានទទួលថវិកាជួយទុន |
| ត្បូងឃ្មុំ | ៣២១អ | ក្រុមហ៊ុន ធីអេច & កូគី ផៅវ័រ ឌីវេឡុបម៉ិន* (គម្រោងទី៥) | - | - | ៣៦២ ដើម | ៥១ដើម | បានទទួលថវិកាជួយទុន |
| | **សរុប I** | | **១៧២,៣៨** | **១៨៣,៧៩** | **១៦៧,៨៨** | **១៦៤,៣៩** | |
| | | | **៣៥៦,១៧** | | **៣៣២,២៧** | | |
| **II គម្រោងថវិកាផ្តល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់** | | | | | | | |
| បន្ទាយមានជ័យ | ៤០១អ | លោក តាន់ លាងស្រេង (គម្រោងទី៤) | ៦,០០ | ៨,៥០ | ៦,០០ | ៨,៥០ | បានទទួលថវិកាជួយទុន |
| បាត់ដំបង | ២០២អ | សហគ្រាស អគ្គិសនី គង់ សាម៉ុន (គម្រោងទី៥) | ១២,១០ | ៨,៣០ | ១២,១០ | ៨,៣០ | បានទទួលថវិកាជួយទុន |
| កំពង់ឆ្នាំង | ៤០០អ | លោក ហុង សេងគ្រី* (គម្រោងទី៨) | ៧,៣០ | ៣,០០ | ៧,៣០ | ៣,០០ | បានទទួលថវិកាជួយទុន |
| | ៤២៤អ | លោក សួន សុផានិត (គម្រោងទី៣) | ១៣,៥០ | ១២,០០ | ១៣,៥០ | ១២,០០ | បានទទួលថវិកាជួយទុន |
| កំពង់ធំ | ៣២៨អ | លោក សៀង ទី(គម្រោងទី២) | ១២,៩០ | - | ១២,៩០ | - | បានទទួលថវិកាជួយទុន |
| | ៣៨៧អ | សហគ្រាស អេច ជី អ ជី អេឡិកទ្រីស៊ីធី អេនធើប្រាយ (គម្រោងទី៤) | ១,៣០ | ១២,២១ | ១,៣០ | ១២,២១ | បានទទួលថវិកាជួយទុន |
| | ៣២៦អ | សហគ្រាស វណ្ណា ឡៃហ៊ីម អេឡិកទ្រីស៊ីធី (គម្រោងទី៤) | - | - | ២៦ដើម | ១៩១ដើម | បានទទួលថវិកាជួយទុន |
| កោះកុង | ៣៧០អ | ក្រុមហ៊ុន កោះកុង ឌីស្ទ្រីក (គម្រោងទី៣) | - | - | ១០៩ដើម | - | បានទទួលថវិកាជួយទុន |
| | ៤១៨អ | លោកស្រី ឆេង ទូច (គម្រោងទី៥) | - | - | ១៣៥ដើម | ២១០ដើម | បានទទួលថវិកាជួយទុន |
| ព្រះវិហារ | ៣៣៤អ | ក្រុមហ៊ុន អគ្គិសនី អេស ឌី គូលែន (គម្រោងទី៤) | ៩,១០ | - | ៩,១០ | - | បានទទួលថវិកាជួយទុន |
| | ៤០៩អ | លោក អេង សុជាវឌ្ឍនា (គម្រោងទី៣) | ៤,៥៤ | ២,០០ | - | - | កំពុងសាងសង់ |
| ព្រៃវែង | ០៣៦អ | លោកស្រី ពោជ គីម (គម្រោងទី៤) | ២,០១ | ០,៥០ | - | - | កំពុងសាងសង់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ៣៥៥អ | សហគ្រាស ឈរ វ៉េងងួន អេឡិចទ្រិស៊ីធី អេនធើប្រាយ (គម្រោងទី៨) | ២០,៨០ | ១៣,៥០ | ២០,៨០ | ១៣,៥០ | បានទទួលថវិកាជួយទុន |
| ពោធិ៍សាត់ | ២៨១អ | លោក វង្ស សំបូរ (គម្រោងទី៦) | ៥,០០ | ៣,៧០ | - | - | កំពុងសាងសង់ |
| | ៣៣២អ | ក្រុមហ៊ុន តាលោ អេលិកទ្រិស៊ីធី (គម្រោងទី៤) | ១២,០០ | - | ១២,០០ | - | បានទទួលថវិកាជួយទុន |
| | ៣៨២អ | លោកស្រី គឹម ស៊ីផល (គម្រោងទី៦) | ៣,០០ | - | ៣,០០ | - | បានទទួលថវិកាជួយទុន |
| | ៣៩៧អ | លោក ប៉ាវ វុទ្ធា (គម្រោងទី៦) | ៧,១០ | ៣,៦០ | - | - | កំពុងសាងសង់ |
| សៀមរាប | ២៤០អ | ក្រុមហ៊ុន ហ៊ាង គឹមហេង អេចអេស ផៅវ័រ* (គម្រោងទី១០) | ១៨,៨០ | ១៥,២០ | ១៨,៨០ | ១៥,២០ | បានទទួលថវិកាជួយទុន |
| ស្វាយរៀង | ៣១៩អ | ក្រុមហ៊ុន ខ្មែរយូធីឡឺធី ត្រេឌីង ខមភេនី (ខេយូធី) (គម្រោងទី៨) | ១២,០០ | ២៦,៧១ | ១២,០០ | ២២,៦៧ | បានទទួលថវិកាជួយទុន និងបិទគម្រោង |
| | **សរុប II** | | **១៤៧,៤៥** | **១០៩,២២** | **១២៥,៨០** | **៩៥,៣៨** | |
| | | | **២៥៦,៦៧** | | **២២១,១៨** | | |
| **សរុប I+II** | | | **៣១៩,៨៣** | **២៩៣,០១** | **២៩៣,៦៨** | **២៥៩,៧៧** | |
| | | | **៦១២,៨៤** | | **៥៥៣,៤៥** | | |

**សំគាល់៖** * តំបន់ធ្វើសេវាកម្មស្ថិតក្នុងខេត្តចំនួន២ និង ** តំបន់ធ្វើសេវាកម្មស្ថិតក្នុងខេត្តចំនួន៣។

**ឧបសម្ព័ន្ធទី១២**

**បញ្ជីឈ្មោះភូមិតាមខេត្តនីមួយៗដែលគ្របដណ្តប់តាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអេភិវឌ្ឍន៍អាល្លឺម៉ង់**
**ក្រោមកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២៣**

| លរ | ខេត្ត/រាជធានី | ភូមិ | ឃុំ | ស្រុក | លេខអាជ្ញាបណ្ណ | អ្នកកាន់អាជ្ញាបណ្ណ |
|---|---|---|---|---|---|---|
| **I ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា** | | | | | | |
| ១ | បន្ទាយមានជ័យ | ភូមិឪម៉ាល់ | ប្រាសាទ | ព្រះនេត្រព្រះ | ១៦៤អ | ក្រុមហ៊ុន វឌ្ឍនៈ អិន.ធី.អង្គរ (គម្រោងទី៤) |
| | | ភូមិកំពង់ក្រសាំង ភូមិកាបៅ | ភ្នំលៀប | ព្រះនេត្រព្រះ | ៥០៤អ | លោក សុក វិច័យ |
| | | ភូមិបឹងវែង | តាឡំ | មង្គលបុរី | | |
| | | ភូមិផ្កាវថ្មី ភូមតាសល់ | គោកបល្ល័ង្គ | | | |
| | | ភូមិស្រណាល ភូមិឡ ភូមិសំបួរ ភូមិក្បាលក្របី ភូមិស្រះឈូក ភូមិស្រែព្រៃ | សំបួរ | | | |
| ២ | កំពង់ស្ពឺ | ភូមិស្រែត្រោក ភូមិព្រៃរំដួល ភូមិវាលវង់ ភូមិស្វាយតាវង | សែនដី | សំរោងទង | ១២៤អ | ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី ** (គម្រោងទី៦) |
| | | ភូមិក្រាំងស្វាយ ភូមិព្រៃសាលា ភូមិស្ពានតោ | រលាំងគ្រើល | | | |
| | | ភូមិតានាង ភូមិអូរសំបូរ | ក្រាំងអំពិល | | | |
| | | ភូមិប្រវឹកពង | ទឹកល្អក់ | គងពិសី | | |
| | | ភូមិពង្រ ភូមិស្រង់ | ស្រង់ | | | |
| | | ភូមិក្រវៀក | ត្រពាំងជោរ | ឱរ៉ាល់ | ៤៣៥អ | លោកស្រី កែវ សេដា ** (គម្រោងទី៣) |
| ៣ | កំពត | ភូមិស្រែចែង ភូមិពងទឹក | ស្រែចែង | ជុំគិរី | ១៩៧អ | សហគ្រាស អេឡិកទ្រីស៊ីធី អង្គរកា (គម្រោងទី៨) |
| ៤ | ក្រចេះ | ភូមិស្រែទ្រៀក ភូមិប្រឡាយទ្រៀក | ដំរីផុង | ស្រុកឆ្លូង | ៣២១អ | ក្រុមហ៊ុន ធីអេច & កូគី ផៅវ័រ ឌីវេឡុបមិន (គម្រោងទី៥) |
| | | ភូមិរលៀក ភូមិវាលកន្សែង | កំពង់ដំរី | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | | ភូមិត្រពាំងសែនជ័យ៥ ភូមិត្រពាំងសែនជ័យ៤ ភូមិត្រពាំងរម៉ាស់ ភូមិត្រពាំងសែនជ័យ៣ ភូមិត្រពាំងសែនជ័យ២ ភូមិត្រពាំងសែនជ័យ១ ភូមិវាល៣ | ត្រញូងសែនជ័យ | ស្ទួល | ៣៥២អ | ក្រុមហ៊ុន អេឡិចទ្រីស៊ីធីខេ៣ (គម្រោងទី២) |
| ៥ | ព្រះវិហារ | ភូមិចំបក់ផ្អែម ភូមិត្រពាំងឫស្សី | រស្មី | រវៀង | ១២៨អ | សហគ្រាស អៀង ខន អេឡិកទ្រីស៊ីធី អានុភាព តំបន់ភ្នំលាក់កេរ (គម្រោងទី៣) |
| | | ភូមិថ្លែង ភូមិកក់ពោន | រហ័ស | | | |
| | | ភូមិសំរិទ្ធ ភូមិព្រៃស្នួល ភូមិកេរ្តិ៍ ភូមិសំព្រោង | រតនៈ | | | |
| | | ភូមិគោកស្រឡៅ | ជាំក្សាន្ត | ជាំក្សាន្ត | ១៦២អ | ក្រុមហ៊ុន ឡេង អ៊ង អេឡិចទ្រីស៊ីធី (គម្រោងទី៤) |
| | | ភូមិត្រពាំងធំ | ទឹកក្រហម | | | |
| | | ភូមិស្រែ ភូមិស្វាយ ភូមិគោក ភូមិរលំថ្ម | រំដោះស្រែ | | | |
| ៦ | ពោធិ៍សាត់ | ភូមិសារៀង ភូមិតាមោលី ភូមិចំរេះ ភូមិសែនជ័យ ភូមិចំកាតាប៉ូ ភូមិក្ដីស្ថិត ភូមិព្រីងខ្ពស់ ភូមិថ្មី ភូមិផ្ទះព្រីង ភូមិបន្ទាយត្រោក ភូមិផ្ទះកោះ ភូមិទួលគូ ភូមិវាល ភូមិត្រង់ ភូមិធ្លាអំពិល ភូមិគៀន | ស្រែស្តុក | កណ្ដៀង | ៣៨៣អ | លោកស្រី គឹម ស៊ីផល (គម្រោងទី៥) |
| | | ភូមិកកោះ ភូមិជ្រៃង ភូមិសន្លុង | ស្វាយលួង | | | |
| | | ភូមិកោះជុំ | កោះជុំ | | | |
| | | ភូមិស្យា | ស្យា | | | |
| | | ភូមិផ្ទះគរ | អន្លង់វិល | | | |
| | | ភូមិធ្លាម្អម ភូមិពោធិ៍អង្ក្រង | បឹងកន្ទួត | ក្រគរ | ៥០១អ | ក្រុមហ៊ុន អគ្គិសនី បឹងកន្ទួត |
| | | ភូមិកំពង់ឡ ភូមិពោធិ៍កុដិ ភូមិទួលទទឹង ភូមិរលួសខាងកើត ភូមិស្នាពច | កំពង់ពោធិ៍ | | | |
| | | ភូមិចំបក់ធំ ភូមិបឹងវាល ភូមិថ្មី | ត្នោតជុំ | | | |
| ៧ | រតនគិរី | ភូមិលោម | ម៉ាលិក | អណ្ដូងមាស | ៣៧២អ | លោក ស៊ាវ ពិសិដ្ឋ (គម្រោងទី៣) |
| | | ភូមិកាដូត ភូមិកេត | ញ៉ាង | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | | ភូមិកានង ភូមិកាតែ ភូមិអ៊ិន | តាឡាវ | | | |
| ៨ | សៀមរាប | ភូមិម្អាក់ ភូមិតាលៀន | គោកធ្លកលើ | ដីក្រែង | ១១១អ | សហគ្រាស អគ្គិសនី គង់ វុន (គម្រោងទី៧) |
| | | ភូមិដុបត្នោត ភូមិស្រឡៅស្រោង ភូមិព្រៃថ្នា | ពង្រលើ | | | |
| | | ភូមិដងផ្អាវ ភូមិផ្លូង ភូមិជ័យបូរ ភូមិសំបួរ ភូមិអូររូង | ពង្រក្រោម | | | |
| ៩ | តាកែវ | ភូមិព្រៃក្ដួច | ត្រពាំងក្រញ៉ូង | ត្រាំកក់ | ១៩៧អ | សហគ្រាស អេឡិកទ្រីស៊ីធី អង្គរការ (គម្រោងទី៨) |
| | | ភូមិឫស្សីមួយគុម្ព ភូមិត្រពាំងក្រឡាញ់ | អូរសារាយ | | | |
| | | ភូមិពាក់បង្អោង ភូមិអង្គត្រាវ ភូមិត្រពាំងស្វាយ | ត្រពាំងធំជើង | | | |
| | | ភូមិព្រៃព្រាល ភូមិត្រពាំងសោម | ត្រពាំងធំត្បូង | | | |
| | | ភូមិក្របីព្រៃ | សំរោង | | | |
| | | ភូមិត្រពាំងព្រីង ភូមិតាលាក់ជើង ភូមិត្រពាំងថ្ម ភូមិពង់ទឹកជើង | គុស | | | |
| | | ភូមិសែនអោក | ត្រាំកក់ | | | |
| | | ភូមិព្រៃក្ដួច | ត្រពាំងក្រញ៉ូង | | | |
| ១០ | ត្បូងឃ្មុំ | ភូមិថ្មដាប់ | រំចេក | មេមត់ | ៣២១អ | ក្រុមហ៊ុន ធីអេច & កូគី ដេវ៉េឡុបមិន(គម្រោងទី៥) |
| | | ភូមិធ្លូង១ ភូមិស្រែសោមចាស់ | កំពាន់ | | | |
| | | ភូមិសាឡង់៣ | គគីរ | | | |
| | | ភូមិជំនុំពល ភូមិល្វាលើ | ជាំតាម៉ៅ | | | |
| | **សរុប** | **១២១ភូមិ** | **៤៧ឃុំ** | **១៦ស្រុក** | | |
| **II ក្រោមថវិកាផ្ដល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់** | | | | | | |
| ១ | បន្ទាយមានជ័យ | ភូមិគោងយាង ភូមិគោកចាស់ ភូមិថ្មីជើង ភូមិថ្មីត្បូង ភូមិស្លែង ភូមិយាងឧត្ដម | ណាំតៅ | ភ្នំស្រុក | ៤០១អ | លោក តាន់ លាងស្រេង (គម្រោងទី៤) |
| ២ | បាត់ដំបង | ភូមិព្រៃទទឹង ភូមិជ្រៃថ្មី ភូមិហៃសាន ភូមិក្បាលខ្មោច ភូមិស្វាយជ្រុំ | ជ្រៃ | ថ្មគោល | ២០២អ | សហគ្រាស អគ្គិសនី គង់ សាម៉ុន (គម្រោងទី៥) |

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | កំពង់ចាម | ភូមិអូរម៉ាល់ | បាជាយ | បាជាយ | ៤០០អ | លោក ហុង សេងគ្រី (គម្រោងទី៨) |
| ៤ | កំពង់ឆ្នាំង | ភូមិបែកចាន ភូមិស្នឹងស្ងួត | អំពិលទឹក | កំពង់ត្រឡាច | ៤០០អ | លោក ហុង សេងគ្រី (គម្រោងទី៨) |
| | | ភូមិកន្លែងភេ | គោកបន្ទាយ | រលាប្អៀរ | ៤២៤អ | លោក សួន សុផានិត (គម្រោងទី៣) |
| | | ភូមិភ្លូង | ពាមឆ្កោក | ជលគីរី | | |
| ៥ | កំពង់ធំ | ភូមិកូនក្អែក ភូមិសំបូរ | សំបូរ | ប្រាសាទសំបូរ | ៣២៦អ | សហគ្រាស វណ្ណា ឡៃហ៊ីម អេឡិកទ្រី ស៊ីធី (គម្រោងទី៤) |
| | | ភូមិបឹងខ្វែក ភូមិឈូកគ្រួស ភូមិស្វាយ | ស្រើង | | | |
| | | ភូមិគោកស្រុក | តាំងក្រសៅ | | | |
| | | ភូមិវល្លិយាវ | កំពង់ស្វាយ | កំពង់ស្វាយ | ៣៨៧អ | សហគ្រាស អេច ជី អ ជី អេឡិកទ្រី ស៊ីធី អេនជើប្រាយ (គម្រោងទី៤) |
| | | ភូមិព្រៃគុយ | ព្រៃគុយ | | | |
| | | ភូមិកូនត្នោត ភូមិសាលាពពេល | ជ័យ | | | |
| | | ភូមិត្រពាំងក្រោល ភូមិបុស្សវែង ភូមិឫស្សីដ្ជូច ភូមិវាលល្អក់ | សាលាវិស័យ | ប្រាសាទបល្ល័ង្គ | | |
| ៦ | កោះកុង | ភូមិជ្រោយប្រស់ | ជ្រោយប្រស់ | កោះកុង | ៣៧០អ | ក្រុមហ៊ុន កោះកុង ឌីស្ទ្រីក (គម្រោងទី៣) |
| | | ភូមិដីទំនាប | ត្រពាំងរូង | | | |
| | | ភូមិអូរម្លូរ ភូមិទឹកល្អក់ | ថ្មដូនពៅ | ថ្មបាំង | ៤១៨អ | លោកស្រី ឆេង ទូច (គម្រោងទី៥) |
| | | ភូមិទឹកល្អក់ ភូមិកោះ ភូមិព្រែកស្វាយ | ជីផុត | | | |
| ៧ | ព្រៃវែង | ភូមិពោធិ៍រៀងជើង ភូមិពោធិ៍រៀងត្បូង ភូមិយាយសល់ | ពោធិ៍រៀង | ពោធិ៍រៀង | ៣៥៥អ | សហគ្រាស ឈរ វែងងួន អេឡិកទ្រី ស៊ីធី អេនជើប្រាយ (គម្រោងទី៨) |
| | | ភូមិថ្មី | ព្រៃផ្ទះ | | | |
| | | ភូមិជ្រាវ ភូមិព្រែកន្លោង | ព្រែកន្លោង | | | |
| ៨ | ពោធិ៍សាត់ | ភូមិតាលោ ភូមិតាំងគោក ភូមិទួលទទឹង ភូមិសំសាន្ត ភូមិព្រៃតោ ភូមិថ្មី | តាលោ | តាលោសែនជ័យ | ៣៣២អ | ក្រុមហ៊ុន តាលា អេឡិចទ្រិចស៊ីធី សឹបផ្លាយ (គម្រោងទី៧) |

| | | | | | | |
|---|---|---|---|---|---|---|
| ៩ | សៀមរាប | ភូមិសមុទ្រ ភូមស្រែពោធិ៍ ភូមិស្រែណូយ | ស្រែណូយ | វ៉ារិន | ២៤០អ | ក្រុមហ៊ុន ហ៊ាង គឹមហេង អេចអេស ផៅវ័រ (គម្រោងទី១០) |
| | | ភូមិខ្នារក្រៅ ភូមិកន្ទួត | កន្ទួត | ស្វាយលើ | | |
| | | ភូមិខ្នារវាស | ឃុនរាម | បន្ទាយស្រី | | |
| ១០ | ស្វាយរៀង | ភូមិវត្ត ភូមិត្រពាំងបន្ទាយ ភូមិម្រាក់ទាប ភូមិវាលត្នាត ភូមិវាលវែង ភូមិពពូល ភូមិតាសួស ភូមិត្រស់ | ត្រស់ | រមាសហែក | ៣១៩អ | ក្រុមហ៊ុន ខ្មែរយូជីឡឺជី ត្រេឌីង (គម្រោងទី៨) |
| | | ភូមិត្រោក ភូមិស្រែឬស្សី ភូមិរមាសហែក | អំពិល | | | |
| | | ភូមិត្នាតពង ភូមិបិតមាស | សំបូរ | | | |
| | | ភូមិតាសេក | គគីរ | | | |
| **សរុប** | | **៦៩ភូមិ** | **២៨ឃុំ** | **១៧ស្រុក** | | |
| **សរុបរួម** | | **១៩០ភូមិ** | **៧៥ឃុំ** | **៣៣ស្រុក** | | |

**សំគាល់៖**- ក្នុងចំណោម ៥២៦ភូមិ មាន ៤ភូមិ បានអនុវត្តក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងថវិកាផ្តល់ដោយ ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ត្រួតគ្នា។

- * តំបន់ធ្វើសេវាកម្មស្ថិតក្នុងខេត្តចំនួន២ **តំបន់ធ្វើសេវាកម្មស្ថិតក្នុងខេត្តចំនួន៣។

# ឧបសម្ព័ន្ធទី១៣

## ផែនទីបង្ហាញពីខេត្តដែលបានអនុវត្តកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអេកិវ៉ឌ្ឍន៍អាល្លឺម៉ង់ ក្នុងឆ្នាំ២០២៣



# ឧបសម្ព័ន្ធទី១៤

## ព័ត៌មានសង្ខេបស្ដីពីចំនួនអតិថិជនដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីជូនអ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២៣ (ខួបឆ្នាំ២០២២)

| លរ | ខេត្តក្រុង | អតិថិជន | | | | | | សរុបអតិថិជន |
|---|---|---|---|---|---|---|---|---|
